ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន
# សម្រាប់វិស័យអប់រំ



២០១៩

# បុព្វកថា

បច្ចុប្បន្ននេះ គ្រោះមហន្តរាយ និងបម្រែបម្រួលអាកាសធាតុកំពុងបង្កហានិភ័យដល់ការរស់នៅ របស់ប្រជាពលរដ្ឋជាទូទៅដែលកំពុងក្លាយជាបញ្ហាចម្បងសម្រាប់យើងទាំងអស់គ្នា និងពិភពលោកទាំងមូល ត្រូវយកចិត្តទុកដាក់ខ្លាំង ដោយត្រូវរិះរកវិធានការដោះស្រាយឱ្យបានទាន់ពេល និងមានប្រសិទ្ធភាព តាមរយៈការចូលរួមអនុវត្តកម្មវិធី និងគម្រោងនានាដែលរាជរដ្ឋាភិបាលបានដាក់ចេញស្របតាមក្របខណ្ឌការងារក្នុងតំបន់ និងពិភពលោក។

ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតឡើងនូវផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយដោយផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងក្របខណ្ឌការងារសេនដាយ ស្តីពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយជាសាកល ២០១៥-២០៣០ អង្គការសហប្រជាជាតិ នៅទីក្រុងសេនដាយ ប្រទេសជប៉ុនកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ និងក្របខណ្ឌរួមអាស៊ាន ស្តីពីសាលារៀនសុវត្ថិភាព កិច្ចព្រមព្រៀងអាស៊ាន ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបការសង្គ្រោះបន្ទាន់ដោយបានចូលជាធរមានកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ សំដៅកាត់បន្ថយការបាត់បង់អាយុជីវិត ការខាតបង់ផ្នែកសេដ្ឋកិច្ចសង្គម រូបវ័ន្ត បរិស្ថាន និងទ្រព្យសម្បត្តិ ដែលបង្កដោយគ្រោះមហន្តរាយធម្មជាតិ និងមនុស្ស។

ដោយអនុលោមតាមកិច្ចព្រមព្រៀង និងក្របខណ្ឌការងារខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ដោយតម្រូវឱ្យក្រសួង ស្ថាប័ន បង្កើតយន្តការ គ្រប់គ្រងគ្រោះមហន្តរាយតាមវិស័យរបស់ខ្លួនដើម្បីត្រៀមបង្ការ កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងឆ្លើយតបប្រកបដោយប្រសិទ្ធភាពទាន់ពេល ក្នុងគ្រាមានគ្រោះមហន្តរាយ។ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតយន្តការគ្រប់គ្រង និងកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននេះដោយបញ្ជ្រាប ទៅក្នុងផែនការយុទ្ធសាស្រ្តវិស័យអប់រំ ។ ផែនការនេះ ជាឯកសារជំនួយស្មារតីដ៏មានសារៈសំខាន់ សម្រាប់ធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ និងជាផែនទីបង្ហាញផ្លូវ សម្រាប់មន្ត្រីអប់រំថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន ដើម្បីអនុវត្តប្រកបដោយឆន្ទៈនិងទទួលខុសត្រូវតាមតួនាទីនិងភារកិច្ចរៀងខ្លួន។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការគាំទ្រទាំងថវិកា និងបច្ចេកទេសរបស់អង្គការ UNICEF, Save The Children, ChildFund Cambodia, Child Rights Foundation, World Vision International, Plan International, ActionAid Cambodia ជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់ក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា ស្ថាប័នអប់រំនៅគ្រប់លំដាប់ថ្នាក់ និងដៃគូអភិវឌ្ឍន៍នានានឹងខិតខំយកចិត្តទុកដាក់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ និងអនុវត្តផែនការនេះប្រកបដោយស្មារតីទទួលខុសត្រូវ ការច្នៃប្រឌិតព្រមទាំងធានាបាននូវគុណភាពនិងប្រសិទ្ធភាពខ្ពស់។ ៤

ថ្ងៃព្រហស្បតិ៍ ២កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៣៥៤៣ អយក.ភខន

## លិខិតឧទ្ទេសនាម

**យោង ៖** -ផែនការសកម្មភាព AOP របស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា២០១៨ និងផែនការសកម្មភាពការងារគ្រប់គ្រងគ្រោះមហន្តរាយវិស័យអប់រំ២០១៨ របស់លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយក្រសួងអយក។

-កញ្ចប់ថវិការបស់អង្គការយូនីសេហ្វ សម្រាប់គាំទ្រការធ្វើបច្ចុប្បន្នភាពឯកសារផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់វិស័យអប់រំ២០១៤។

-របាយការណ៍កិច្ចប្រជុំពិភាក្សាធ្វើផែនការកែលម្អឯកសារEPR ២០១៤ជាមួយដៃគូពាក់ព័ន្ធ កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ នៅលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយក្រសួងអប់រំ យុវជន និងកីឡា។

ថ្នាក់ដឹកនាំនិងបុគ្គលិកអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាក្រុមការងារកែលម្អឯកសារផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន២០១៤ អភិវឌ្ឍឯកសារមគ្គុទ្ទេសក៍គ្រប់គ្រងគ្រោះមហន្តរាយ និងឯកសារពាក់ព័ន្ធគ្រោះអាសន្ននានាសម្រាប់វិស័យអប់រំ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

### I - គណៈគ្រប់គ្រង

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហង់ ជួន ណារ៉ុន** | | រដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត** | **ប៊ុនរឿន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣-លោកជំទាវ | **គឹម** | **សេដ្ឋានី** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤-ឯកឧត្តមបណ្ឌិត | **អ៊ឹម** | **កុច** | រដ្ឋលេខាធិការ | សមាជិក |
| ៥-ឯកឧត្តម | **ហ៊ាង** | **ស៊ីណោ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៦-ឯកឧត្តម | **ថោង** | **បូរ៉ាន់** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៧-ឯកឧត្តម | **ខួន** | **មាស** | អគ្គនាយកនៃអគ.រប.រហ | សមាជិក |
| ៨-លោក | **លី** | **សទ្ធិ** | អគ្គនាយករងនៃអគ.រប.រហ | សមាជិក |

### II - គណៈកម្មការបច្ចេកទេស

| | | | | |
|---|---|---|---|---|
| ១-លោកជំទាវ | **ទន់** | **សាអ៊ឹម** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២-លោកជំទាវ | **ឃុន** | **រចនា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម | **ចាន់** | **សុតា** | ប្រធាននា.បស | សមាជិក |
| ៤-លោក | **អោ** | **សៀម** | ប្រធាននា.អកស | សមាជិក |
| ៥-លោក | **ព្រីង** | **មរកត** | ប្រធាននា.មចទ | សមាជិក |
| ៦-លោក | **ម៉ៅ** | **ប៉េងឡុង** | ប្រធាននា.បវ | សមាជិក |
| ៧-លោក | **លឹម** | **សុវណ្ណា** | អនុប្រធាននា.សណ | សមាជិក |
| ៨-លោក | **ឃឹម** | **សារិន** | អនុប្រធាននា.អកស | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ / ២១៧ ២៥៣ / ៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

| | | | | |
|---|---|---|---|---|
| ៩-លោកស្រី | **ម៉ៅ** | **តាន់ណាទី** | អនុប្រធានការិ.នា.អកស | សមាជិក |
| ១០-លោកស្រី | ** វ៉ាន់** | **សុគី** | អនុប្រធានការិ.នា.អកស | សមាជិក |
| ១១-លោក | **ឡេង** | **សារី** | អនុប្រធានការិ.នា.អកស | សមាជិក |
| ១២-លោក | **សូ** | **ស៊ីផុន** | អនុប្រធានការិ.នា.អពស | សមាជិក |
| ១៣-លោក | **អេង** | **វ៉ាត់** | អនុប្រធានការិ.នា.អកស | សមាជិក |
| ១៤-លោក | **ទិត្យ** | **ប្រុស** | អនុប្រធានការិ.នា.អកស | សមាជិក |
| ១៥-លោក | **ព** | **ឆួយ** | មន្ត្រីនា.អកស | សមាជិក |
| ១៦-កញ្ញា | **ឈុន** | **សុរិយា** | មន្ត្រីនា.អកស | សមាជិក |
| ១៧-លោកស្រី | **ប៊ុត** | **ច័ន្ទធាវី** | មន្ត្រីនា.បុស | សមាជិក |
| ១៨-លោក | **ដាំ** | **បេង** | មន្ត្រីនា.អកស | សមាជិក |
| ១៩-កញ្ញា | **លន់** | **ច័ន្ទម៉ាឡា** | មន្ត្រីនា.អកស | សមាជិក |
| ២០-លោកស្រី | **សេង** | **ពិសិដ្ឋនារី** | មន្ត្រីនា.អកស | សមាជិក |
| ២១-លោក | **គីម** | **ផេង** | មន្ត្រីនា.អកស | សមាជិក |

### III -តំណាងអង្គការដៃគូអភិវឌ្ឍន៍

| | | |
|---|---|---|
| ១-តំណាងអង្គការយូនីសេហ្វ | UNICEF | សមាជិក |
| ២-តំណាងអង្គការសង្គ្រោះកុមារ | Save the Children | សមាជិក |
| ៣-តំណាងអង្គការក្មេងអន្តរជាតិកម្ពុជា | Plan.Ic | សមាជិក |
| ៤-តំណាងអង្គការអាក់សិនអេតកម្ពុជា | Action Aid Cambodia | សមាជិក |
| ៥-តំណាងអង្គការទស្សនៈពិភពលោក | World Vision | សមាជិក |
| ៦-តំណាងអង្គការឆាលហ្វាន | Child Fund | សមាជិក |
| ៧-តំណាងអង្គការមូលនិធិសិទ្ធិកុមារ | CRF | សមាជិក |
| ៨-តំណាងអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលNEP | | សមាជិក |

- គណៈកម្មការនេះមានភារកិច្ចធ្វើបច្ចុប្បន្នភាពផែនការEPRP ឯកសារមគ្គុទ្ទេសក៍គ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិថ្នាក់ក្រោមជាតិ និងឯកសារគាំទ្រនានាដែលពាក់ព័ន្ធនឹងគ្រោះអាសន្នសម្រាប់វិស័យអប់រំ។
- សមាជិក សមាជិកាទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការតាមការកំណត់។
- គណៈកម្មការខាងលើមានសិទ្ធិជ្រើសរើសសមាជិកបន្ថែមតាមការចាំបាច់។

ថ្ងៃ ៧រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**កន្លែងទទួល ៖**

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីជន «ដើម្បីអនុវត្ត»
-ឯកសារ -កាលប្បវត្តិ នា.អកស

# អារម្ភកថា

ឯកសារ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន សម្រាប់វិស័យអប់រំ សម្រាប់ឆ្នាំ ២០១៩ ត្រូវបានរៀបចំឡើងដោយមានការចូលរួមពី តំណាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងអប់រំ យុវជន និងកីឡា ដែលមានសមាសភាពមកពីនាយកដ្ឋានពាក់ព័ន្ធ មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត និងដៃគូអភិវឌ្ឍន៍រួមមានអង្គការ UNICEF, Save the Children, ChildFund Cambodia, Child Rights Foundation, World Vision International, Plan International, ActionAid Cambodia ដែលបានជួយឧបត្ថម្ភទាំងថវិកា និងបច្ចេកទេស ក្រោមការដឹកនាំ សម្របសម្រួលពីឯកឧត្តមថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា រហូតសម្រេចបានជាសៀវភៅផែនការនេះឡើង។

ឯកសារនេះបង្កើតឡើង ផ្អែកលើគោលការណ៍ណែនាំស្តីពីផែនការជាតិត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះមហន្តរាយ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដោយមានការជួយផ្តល់ប្រឹក្សាបច្ចេកទេស មកពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលជាទីប្រឹក្សាបច្ចេកទេសរបស់ក្រសួង និងមន្ត្រីនាយកដ្ឋានពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍន៍តាមរយៈការធ្វើសិក្ខាសាលាពង្រឹងសមត្ថភាព រៀបចំសេចក្តីព្រាង និងពិគ្រោះយោបល់។

ខ្លឹមសារក្នុងផែនការសកម្មភាពនេះ ជាជំនួយស្មារតីក្នុងការធ្វើសេចក្តីសម្រេចចិត្តដើម្បីអនុវត្តផែនការ បានសមស្របនិងមានប្រសិទ្ធភាព ដែលទាមទារឱ្យមានការចូលរួមអនុវត្តទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពិសេសសាលារៀន និងស្ថាប័នពាក់ព័ន្ធដទៃទៀត។ តាមរយៈផែនការនេះ លេខាធិការដ្ឋាន និងអនុគណៈកម្មការទាំងបីនៃយន្តការគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងអប់រំ យុវជន និងកីឡា នឹងបានត្រៀមខ្លួនទាន់ពេលវេលាសម្រាប់ការងារឆ្លើយតបគ្រោះអាសន្នក្នុងវិស័យអប់រំ។

ក្រុមការងារថ្នាក់ជាតិកែលម្អឯកសារ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់វិស័យអប់រំ សង្ឃឹមយ៉ាងមុតមាំថា ផែនការនេះនឹងបានជាប្រយោជន៍ដ៏មានសារៈសំខាន់បំផុតសម្រាប់អ្នកពាក់ព័ន្ធក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំ ឆ្លើយតបគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

**គណៈកម្មការនិពន្ធ**

# មាតិកា


បុព្វកថា ----------------------------------------------------------------------------------
លិខិតឧទ្ទេសនាមក្រុមការងារ ---------------------------------------------------------------
អារម្ភកថា --------------------------------------------------------------------------------
មាតិកា -----------------------------------------------------------------------------------
អក្សរកាត់ --------------------------------------------------------------------------------
ម្ចាស់មូលនិធិនិងអង្គការដៃគូ -----------------------------------------------------------------
១. សេចក្តីផ្តើម ------------------------------------------------------------------------- ១
២- បរិបទទូទៅ ------------------------------------------------------------------------------៣
៣- ក្របខណ្ឌគតិយុត្តិ-------------------------------------------------------------------- ៤
៤. រចនាសម្ព័ន្ធ និងយន្តការសម្របសម្រួល ----------------------------------------------- ៦
៥. ផលប៉ះពាល់នៃគ្រោះមហន្តរាយលើវិស័យអប់រំ--------------------------------------១២
៦. សេណារីយ៉ូ និងការតាមដានហានិភ័យគ្រោះមហន្តរាយ-----------------------------១៧
៧. ប្រព័ន្ធព័ត៌មានឱ្យដឹងជាមុន ១២៩៤ ------------------------------------------------- ២៣
៨. សកម្មភាពត្រៀមបង្ការអប្បបរមា និងកាត់បន្ថយហានិភ័យ
មុនគ្រោះមហន្តរាយ ------------------------------------------------------------------២៥
៩. ផែនការឆ្លើយតបបន្ទាន់ទៅនឹងគ្រោះទឹកជំនន់ ----------------------------------- ៣២
ឧបសម្ព័ន្ធ ១៖ ប្រកាសលេខ១៣៥៣--------------------------------------------------------៤១
ឧបសម្ព័ន្ធ ២៖ ភារកិច្ច និងការទទួលខុសត្រូវនៃយន្តការ
គ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងអប់រំ យុវជន និងកីឡា-----------------------៤៧
ឧបសម្ព័ន្ធ ៣៖ បញ្ជីទំនាក់ទំនងរបស់ក្រុមការងារ----------------------------------------៥២
ឧបសម្ព័ន្ធ ៤៖ បញ្ជីទំនាក់ទំនងរបស់មន្ទីរ និងអង្គការដៃគូពាក់ព័ន្ធ --------------------- ៥៤
ឧបសម្ព័ន្ធ ៥៖ ផែនទីនៃតំបន់គោលដៅរបស់អង្គការដៃគូពាក់ព័ន្ធក្នុងឆ្នាំ២០១៨ -----៥៧
ឧបសម្ព័ន្ធ ៦៖ ស្តង់ដាសម្ភារៈសិក្សា សម្រាប់បង្កើតកន្លែងរៀនបណ្តោះអាសន្ន-------- ៥៨
ឧបសម្ព័ន្ធ ៧៖ ឧបករណ៍សម្រាប់ប៉ាន់ប្រមាណឆាប់រហ័សអំពីផលប៉ះពាល់
នៃគ្រោះមហន្តរាយលើវិស័យអប់រំ ------------------------------------------------ ៥៩
ឧបសម្ព័ន្ធ ៨៖ សទ្ទានុក្រម ---------------------------------------------------------------៦៦

# អក្សរកាត់

| | |
|---|---|
| AADMER | ASEAN Agreement on Disaster Management and Emergency Response |
| DM Law | Disaster Management Law |
| ECHO | European Commission's department for overseas humanitarian aid and for civil protection |
| NCDM | National Committee for Disaster Management |
| RGC | Royal Government of Cambodia |
| UNDP | United Nation Development Program |
| UNICEF | United Nations Children's Fund |
| USAID | United States Agency for International Development |
| អយក. | ក្រសួងអប់រំ យុវជន និងកីឡា |
| សណន. | សេចក្ដីណែនាំ |
| ប្រក | ប្រកាស |
| អគ.ផគ | អគ្គនាយកដ្ឋានផែនការនិងគោលនយោបាយ |
| អគ.អរ | អគ្គនាយកដ្ឋានអប់រំ |
| អគ.រហ | អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ |
| នា.អកស | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| នា. រប | នាយកដ្ឋានរដ្ឋបាល |
| នា.មចទ | នាយកដ្ឋានមធ្យមសិក្សា ចំណេះទូទៅ |
| នា.បវ | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រិតការ |
| នា.ពអ | នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានអប់រំ |
| នា.ឧស | នាយកដ្ឋានឧត្តមសិក្សា |
| នា.សណ | នាយកដ្ឋានសំណង់ |
| នា.សទរ | នាយកដ្ឋានសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ |

| | |
|---|---|
| នា.ហវ | នាយកដ្ឋានហិរញ្ញវត្ថុ |
| នា.អកត | នាយកដ្ឋានអប់រំកុមារតូច |
| នា.សស | នាយកដ្ឋានសុខភាពសិក្សា |
| នា.ពវ | នាយកដ្ឋានពិនិត្យតាមដាននិងវាយតម្លៃ |
| នា.បល | នាយកដ្ឋានបុគ្គលិក |
| នា.ផក | នាយកដ្ឋានផែនការ |
| នា.អកស | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ការិ.នា.សណ | ការិយាល័យ នាយកដ្ឋានសំណង់ |
| ការិ.នា.សទរ | ការិយាល័យ នាយកដ្ឋានសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ |
| ការិ.នា.អពស | ការិយាល័យ នាយកដ្ឋានអប់រំពិសេស |

## ម្ចាស់មូលនិធិនិងអង្គការដៃគូ

| | |
|---|---|
| AAC | ActionAid Cambodia |
| CFC | ChildFund Cambodia |
| CRF | Child Rights Foundation |
| Plan Int. | Plan International |
| SCI | Save the Children International |
| UNICEF | United Nations Children's Fund |
| WVI | World Vision International |

# ១. សេចក្តីផ្តើម

ការកើតឡើងញឹកញាប់និងធ្ងន់ធ្ងរនៃគ្រោះមហន្តរាយ ព្រមទាំងការប្រែប្រួលអាកាសធាតុក្នុងពិភពលោក និងតំបន់ កំពុងជះឥទ្ធិពលអាក្រក់ឡើងៗដល់ការរស់នៅរបស់ប្រជាពលរដ្ឋទូទៅ។ បញ្ហាទាំងនោះបានក្លាយជាកត្តាប្រឈមជាច្រើនដែលយើងទាំងអស់គ្នានិងពិភពលោកទាំងមូលត្រូវយកចិត្តទុកដាក់ខ្ពស់ ដោយចាត់វិធានការដោះស្រាយ ឱ្យបានទាន់ពេលវេលា។ ពិសេសការចូលរួមអនុវត្តកម្មវិធី ឬគម្រោងនានាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ស្របតាមក្របខណ្ឌការងារក្នុងតំបន់ និងពិភពលោកក្នុងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព។

ប្រទេសកម្ពុជាត្រូវបានគេចាត់ទុកថាជាប្រទេសដែលងាយរងគ្រោះ និងទទួលរងផលប៉ះពាល់ អវិជ្ជមាន ដោយគ្រោះមហន្តរាយធម្មជាតិញឹកញាប់ដូចជា គ្រោះទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ រន្ទះបាញ់ ជំងឺរាតត្បាត និងមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗជាច្រើនទៀត។ ទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារគ្រោះទឹកជំនន់ក្នុងឆ្នាំ២០០០ ២០០១ ២០១១ ២០១៣ និងឆ្នាំ២០១៨ គ្រោះរាំងស្ងួតឆ្នាំ២០១៥ និងខ្យល់ព្យុះឆ្នាំ២០០៩(កេតសាណា)។ ផលប៉ះពាល់ទាំងនោះបានធ្វើឱ្យខូចខាត ទ្រព្យសម្បត្តិសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម ធ្វើឱ្យប្រជាពលរដ្ឋរាប់លាននាក់ជួបការលំបាកក្នុងការប្រកបរបរចិញ្ចឹមជីវិត បាត់បង់ជម្រក និងចំណាកស្រុកដោយមិនមានសុវត្ថិភាព។ កត្តាទាំងអស់នេះបាននឹងកំពុងធ្វើឱ្យប៉ះពាល់ដល់វិស័យអប់រំយ៉ាងខ្លាំង។

នៅចុងឆ្នាំ២០១៣ ក្រសួងអប់រំ យុវជន និងកីឡាបានវាយតម្លៃផលប៉ះពាល់លើវិស័យអប់រំ ដោយសារគ្រោះទឹកជំនន់ ហើយបានរកឃើញសាលារៀនចំនួន១២៨០កន្លែង ត្រូវបានទទួលរងផលប៉ះពាល់ ក្នុងនោះមានសាលាយ៉ាងតិចចំនួន១៥៥កន្លែង ត្រូវបានផ្អាកដំណើរការពី១ ដល់៥សប្តាហ៍ បណ្តាលឱ្យកុមារយ៉ាងតិច៥ម៉ឺននាក់ ខកខានមិនបានចូលរៀននៅដើមឆ្នាំសិក្សា២០១៣-២០១៤។ សៀវភៅសិក្សាជាង៤ម៉ឺនក្បាល ត្រូវបានបាត់បង់ និងបំផ្លាញដោយសារទឹកជំនន់។ ការវាយតម្លៃលើការបាត់បង់ និងខូចខាតលើវិស័យអប់រំ ដោយសារគ្រោះទឹកជំនន់នៅឆ្នាំ២០១៣កន្លងមកនេះ គិតជាទឹកប្រាក់អស់ប្រមាណជាង១៥លានដុល្លារ។ បញ្ហាគ្រោះទឹកជំនន់បានក្លាយជាមូលហេតុចម្បងក្នុងចំណោមមូលហេតុចម្បងៗ ដទៃទៀត ដែលជំរុញឱ្យមានការកើនឡើងនូវអត្រាបោះបង់ការសិក្សា និងការធ្លាក់ចុះនូវលទ្ធផលសិក្សារបស់សិស្ស ជាពិសេសនៅតំបន់ទទួលរងផលប៉ះពាល់ដោយសារទឹកជំនន់។

ក្នុងឆ្នាំ២០០៩ ប្រទេសកម្ពុជាបានទទួលរងផលប៉ះពាល់ពីព្យុះកេតសាណា ដែលបណ្តាលឱ្យមនុស្សស្លាប់ចំនួន៤៣នាក់ រងរបួសធ្ងន់ចំនួន៦៧នាក់ និងខូចខាតផ្ទះសម្បែង របរចិញ្ចឹមជីវិតចំនួន ៤៩.០០០គ្រួសារ ស្មើនឹង១៨០.០០០នាក់ ឬ១.៤ភាគរយ នៃប្រជាជនសរុបទូទាំងប្រទេសកម្ពុជា[១]។ ទន្ទឹមនឹងនោះដែរ សាលារៀនចំនួន១.១៦៩ បានរងការខូចខាតដោយស្មើនឹង១២ភាគរយនៃសាលារៀនទូទាំងប្រទេស ក្នុងនោះសិស្សស្លាប់ចំនួន៤នាក់ (លង់ទឹក២នាក់ ដោយសារខ្យល់ព្យុះ២នាក់) សៀវភៅសិក្សា ចំនួន១៦.០០០ ក្បាលខូចខាតទាំងស្រុង[២]។

យោងតាមរបាយកាណ៍ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិត្រឹមខែកក្កដា ឆ្នាំ២០១៨បានរកឃើញថាខ្យល់កន្ត្រាក់ បានធ្វើឱ្យខូចខាតផ្ទះចំនួន២.៦៩៦ ខ្ទង សាលារៀនចំនួន១៨កន្លែង។

ដើម្បីធានានូវដំណើរការសិក្សារបស់សិស្សានុសិស្ស ប្រកបដោយសុវត្ថិភាពក្នុងគ្រាមានគ្រោះទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ រាំងស្ងួត ក្រសួងអប់រំ យុវជន និងកីឡា បានប្រកាសផ្សព្វផ្សាយដល់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត នូវសេចក្តីណែនាំ ស្តីពីការរៀបចំកន្លែងរៀនបណ្តោះអាសន្នក្នុងគ្រាមានគ្រោះអាសន្ន ពិសេសទឹកជំនន់។ ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងចលនាធនធាន ដើម្បីធ្វើយ៉ាងណាចូលរួមកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយទៅតាមលទ្ធភាពដែលអាចធ្វើបាន ក៏ដូចជាការឆ្លើយតបបានទាន់ពេលវេលា តាមរយៈការចាត់ចែង ផ្តល់ការអប់រំប្រកបដោយសុវត្ថិភាពនៅគ្រប់កម្រិត រួមមានអប់រំកុមារតូច បឋមសិក្សា និងមធ្យមសិក្សា។

១. របាយការណ៍គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ( 2009 Post-Ketsana Disaster need assessment report March, 2010) ទំព័រទី ១៥
២ របាយការណ៍គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ( 2009 Post-Ketsana Disaster need assessment report March, 2010) ទំព័រទី ៧១

# ២- បរិបទទូទៅ

ប្រទេសកម្ពុជា មានប្រជាជនសរុបជាង១៤.៦៨លាននាក់[៣] សន្ទស្សន៍កំណើនប្រជាសាស្ត្រ ១.៨ក្នុងនោះ ៤១ភាគរយជាកុមារ និងយុវជនអាយុក្រោម១៨ឆ្នាំ។ ១ ភាគ ៣ នៃប្រជាជនសរុប មានអាយុចន្លោះពី១០ ទៅ២៤ឆ្នាំ ត្រូវបានកត់សម្គាល់ថា ប្រទេសកម្ពុជាមានប្រជាជនអាយុក្រោម១៨ឆ្នាំ ច្រើនជាងគេក្នុងចំណោមបណ្តាប្រទេសនៅអាស៊ីភាគអាគ្នេយ៍។ ប្រជាជន ៨០.៥ភាគរយ រស់នៅតំបន់ជនបទ និង១៩.៥ភាគរយ រស់នៅទីប្រជុំជន។ ក្នុងចំណោម៤គ្រួសារ មាន១គ្រួសារ ដែលមានស្ត្រីជាមេគ្រួសារ។ ភូមិសាស្ត្រនៃប្រទេសកម្ពុជា មានសណ្ឋានដីទំនាបកណ្តាលដែលមានទន្លេមេគង្គ ទន្លេសាប ភ្ជាប់ដោយបឹង ស្ទឹង ព្រែក អូរប្រឡាយរាប់ពាន់ខ្សែ។ តំបន់សមុទ្រនៅប៉ែកនីរតីនៃប្រទេស និងតំបន់ភ្នំ នៅប៉ែកខាងជើង មានជួរភ្នំដងរែក និងខាងត្បូងមានភ្នំក្រវាញ។ មានរាជធានី ខេត្ត យ៉ាងហោចណាស់១៨ លើ២៥ តែងតែប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់ និងគ្រោះមហន្តរាយមានជាអាទិ៍ គ្រោះទឹកជំនន់(ទឹកជំនន់ហ៊ើស និងទឹកជំនន់ទន្លេ) រាំងស្ងួត រន្ទះបាញ់ ខ្យល់ព្យុះ និងខ្យល់កន្ត្រាក់។ គ្រោះមហន្តរាយ គឺជាឧបសគ្គដ៏ធំដល់ដំណើរការអភិវឌ្ឍ សេដ្ឋកិច្ច សង្គម បរិស្ថាន ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍធនធានមនុស្សរបស់ប្រទេសកម្ពុជា(របាយការណ៍ NCDM ២០១៣)។ ជាពិសេសការឈានដល់គោលដៅ ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា នៅមិនទាន់សម្រេចបានតាមការគ្រោងទុក។

## ប្រតិទិនឆ្នាំសិក្សា និងរដូវកាលនៃទឹកជំនន់

យោងតាមសេចក្តីណែនាំស្តីពី ការអនុវត្តវិមជ្ឈការកាលវិភាគ និងប្រតិទិនសិក្សា លេខ ៣៤៣៥ អយក.សណន. ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០។ ក្រសួងអប់រំ យុវជន និងកីឡា បានណែនាំដល់សាលារៀនឱ្យរៀបចំកាលវិភាគសិក្សាស្របតាមស្ថានភាពជាក់ស្តែង ពិសេសនៅតាមតំបន់ដែលទទួលរងគ្រោះដោយសារទឹកជំនន់។

- កាលវិភាគឆ្នាំសិក្សាធម្មតា៖ វិស្សមកាលចាប់ផ្តើម នៅថ្ងៃទី៣១ ខែកញ្ញា និងបវេសនកាលចាប់ផ្តើមចូលរៀននៅថ្ងៃទី១ ខែវិច្ឆិកា ជារៀងរាល់ឆ្នាំ។
- ទឹកជំនន់តែងតែចាប់ផ្តើមនៅខែកក្កដានិងបន្តដល់ខែតុលា ឬវិច្ឆិកា ធ្វើឱ្យប៉ះពាល់ដល់ការរៀន និងបង្រៀន (ទឹកជំនន់អាចអូសបន្លាយដល់ខែវិច្ឆិកា នៅតំបន់ខ្លះតាមដងទន្លេមេគង្គខាងក្រោម)

៣. របាយការណ៍ជំរឿនប្រជាសាស្ត្រឆ្នាំ២០១៣

- ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះទឹកជំនន់ វិស្សមកាលគប្បីពន្យារនៅចន្លោះខែកញ្ញា ដល់តុលា។




## ៣- ក្របខណ្ឌគតិយុត្តិ

- ក្របខណ្ឌសេនដាយ២០១៥-២០៣០ ចំណុចអាទិភាពទី៤ លើកកម្ពស់ការត្រៀមបម្រុងគ្រោះមហន្តរាយ សម្រាប់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងការស្តាបនាឱ្យប្រសើរជាងមុន ក្នុងការស្តារនិងកសាងឡើងវិញ។
- ព្រះរាជក្រម ស/រកម/០២០៨/០០៤ ស្តីពីការប្រកាសឱ្យប្រើប្រាស់ កិច្ចព្រមព្រៀងអាស៊ានការគ្រប់គ្រងគ្រោះមហន្តរាយ និងឆ្លើយតបគ្រោះអាសន្នបន្ទាន់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨។ ប្រការ២ គោលដៅនៃកិច្ចព្រមព្រៀង គឺផ្តល់ជូននូវយន្តការប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចការកាត់បន្ថយជាសំខាន់នូវការបាត់បង់អាយុជីវិតមនុស្សតាមរយៈកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ រួមសហប្រតិបត្តិការជាមួយថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។ ប្រការ៣ ចំណុច៤ ភាគីទាំងឡាយត្រូវផ្តល់អាទិភាពលើការត្រៀមបង្ការ និងការកាត់បន្ថយគ្រោះថ្នាក់ ដើម្បីត្រៀមបង្ការតាមដាន និងកាត់បន្ថយគ្រោះមហន្តរាយ។ ប្រការ៦ ការត្រៀមបង្ការ និងកាត់បន្ថយគ្រោះថ្នាក់។
- ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ប្រកាសឱ្យប្រើថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥។ មាត្រា៨ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ត្រូវបង្កើតយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងក្រសួងស្ថាប័នរបស់ខ្លួន និងត្រូវចាត់ឱ្យមានមន្ត្រីបង្គោលដើម្បីសម្របសម្រួល ...។ មាត្រា១១ សកម្មភាពត្រៀមរៀបចំ ត្រូវផ្តោតលើដំណាក់កាលមុនពេលកើតមានគ្រោះមហន្តរាយ ដោយចាត់វិធានការរៀបចំបង្កើតប្រព័ន្ធប្រកាសឱ្យដឹងជាមុន កសាងយុទ្ធសាស្ត្រ និង

ផែនការត្រៀមបម្រុងឆ្លើយតបសង្គ្រោះបន្ទាន់។ មាត្រា១២ សកម្មភាពឆ្លើយតបសង្គ្រោះបន្ទាន់ត្រូវផ្តោតលើដំណាក់កាលក្នុងពេលមានគ្រោះមហន្តរាយ ...។

- គោលនយោបាយកម្មវិធីសាលាកុមារមេត្រី ឆ្នាំ២០១៦។ សមាសធាតុទី៣ ស្តីពី សុខភាព សុវត្ថិភាព និងការការពារកុមារ ក្នុងគោលបំណង ធានាថាកុមារគ្រប់រូបបានទទួលការអប់រំ និងថែទាំ គាំទ្រដោយស្ថាប័ន និងអ្នកពាក់ព័ន្ធដើម្បីឱ្យកុមារ មានសុខភាពល្អ សុវត្ថិភាព និងការការពារពីអំពើហិង្សានៅសាលារៀន ក្នុងគ្រួសារ និងសង្គម។
- សេចក្តីណែនាំ ស្តីពីការអប់រំក្នុងកម្មវិធីសង្គ្រោះបន្ទាន់ដោយផ្តោតលើ ការរៀបចំទីកន្លែងរៀន ថ្នាក់រៀនមានសុវត្ថិភាពក្នុងពេលមានគ្រោះទឹកជំនន់ លេខ២៧ អ.យ.ក សណន ខែធ្នូ ឆ្នាំ២០១២។
- ប្រកាសលេខ៥៩៥ អយក .ប្រក ស្តីពី ការបង្កើតយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៃក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧។ ប្រការ៩ យន្តការគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួងអប់រំ យុវជន និងកីឡា ...... រៀបចំផែនការប្រចាំឆ្នាំ និងត្រីមាស សម្រាប់គ្រប់គ្រង និងអនុវត្ត ទាំងមុនពេល ក្នុងពេល ទាំងក្រោយពេលគ្រោះមហន្តរាយ។ យោងការចាំបាច់ ឆ្នាំ២០១៩ លេខាធិការដ្ឋានបានធ្វើបច្ចុប្បន្នកម្មទៅលើយន្តការគ្រប់គ្រងគ្រោះមហន្តរាយ តាមប្រកាសលេខ១៣៤៣ អយក .ប្រក ស្តីពី ការបង្កើតយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៃក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ដែលមានភារកិច្ច និងការទទួលខុសត្រូវសំខាន់ៗដូចមានចែងក្នុងឧបសម្ព័ន្ធ២។
- ឯកសារផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់វិស័យអប់រំ២០១៤។ ចំណុចទី៧ យន្តការត្រួតពិនិត្យការអនុវត្តផែនការ និងធ្វើបច្ចុប្បន្នកម្ម។ ដើម្បីសម្របសម្រួលការត្រួតពិនិត្យសកម្មភាពត្រៀមរៀបចំ គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយកម្រិតសាលារៀនត្រូវកោះប្រជុំរៀងរាល់៦ខែម្តង។ ការអនុវត្តសៀវភៅផែនការនេះត្រូវពិនិត្យជារៀងរាល់ឆ្នាំ ហើយអាចធ្វើបច្ចុប្បន្នកម្មក្នុងករណីចាំបាច់។

# ៤. រចនាសម្ព័ន្ធ និងយន្តការសម្របសម្រួល

យោងព្រះរាជក្រមលេខ នស/រកម/០៧១៥/០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

យោងតាមច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ និងផែនការសកម្មភាពជាតិ សម្រាប់កាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ គ្រប់ក្រសួងទាំងអស់ជាសមាជិកនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវរៀបចំផែនការ និងធានាយន្តការក្នុងក្រសួងសាមី និងតាមខ្សែបណ្តោយរបស់ខ្លួន ដើម្បីទទួលខុសត្រូវអនុវត្តសកម្មភាព ដែលបានកំណត់នៅក្នុងផែនការសកម្មភាពជាតិ សម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយឆ្នាំ២០១៤-២០១៨។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំយន្តការសម្រាប់ដំណើរការមុខងារស្ថាប័នរបស់ខ្លួននៅគ្រប់កម្រិតថ្នាក់ រួមមាន៖

- គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រសួងដែលមាន ប្រធាន ឬអនុប្រធាននាយកដ្ឋានជំនាញទាំងអស់ជាសមាជិក។
- គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់មន្ទីរ ដែលមានប្រធានការិយាល័យ ឬមន្ត្រីមកពីការិយាល័យពាក់ព័ន្ធរបស់មន្ទីរអប់រំ យុវជន និងកីឡា ជាសមាជិក។
- គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ការិយាល័យអប់រំស្រុក ដែលមានមន្ត្រីមកពី ការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងនាយកកម្រង ជាសមាជិក។
- គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយកម្រិតសាលារៀន ដែលមានសមាជិក ជានាយកសាលា លោកគ្រូ អ្នកគ្រូ សមាជិកគណៈកម្មការទ្រទ្រង់សាលារៀន និងក្រុមប្រឹក្សាកុមារ។

ដូចនេះ ស្ថាប័នអប់រំនៅគ្រប់កម្រិតថ្នាក់ ជាសមាជិករបស់គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយនៅគ្រប់លំដាប់ថ្នាក់ ដូចជាក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិករបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។ មន្ទីរអប់រំ យុវជន និងកីឡា ជាសមាជិករបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី ខេត្ត។ ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ និងសាលាកម្រងជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំសង្កាត់។

ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុង

ក្រសួង ក្នុងនោះមានរចនាសម្ព័ន្ធដូចខាងក្រោម៖

១. គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយមាន ប្រធាន១រូប និងអនុប្រធាន១រូប ឬមួយចំនួនតាមការចាំបាច់

២. លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយមានប្រធាន១រូប អនុប្រធានមួយចំនួនតាមការចាំបាច់ មន្ត្រីបង្គោល និងសមាជិកមួយចំនួន

៣. ទីប្រឹក្សាជាតិ១រូប តំណាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

៤. គណៈកម្មការបច្ចេកទេសដែលមានអនុគណៈកម្មការចំនួន៣ គឺ

- អនុគណៈកម្មការទី១៖ ទទួលបន្ទុកការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ មានប្រធាន១រូប អនុប្រធាន២ទៅ៣រូប (អនុប្រធានទី១ អនុប្រធានទី២ និងអនុប្រធានទី៣)និងសមាជិក សមាជិកាមួយចំនួនមកពីអគ្គនាយកដ្ឋាន នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។
- អនុគណៈកម្មការទី២៖ ទទួលបន្ទុកការងារត្រៀមរៀបចំឆ្លើយតប និងការងារឆ្លើយតបគ្រោះមហន្តរាយ មានប្រធាន១រូប អនុប្រធាន២រូប ទៅ៣រូប (អនុប្រធានទី១ អនុប្រធានទី២ និងអនុប្រធានទី៣) និងសមាជិក សមាជិកាមួយចំនួនមកពីអគ្គនាយកដ្ឋាន នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។
- អនុគណៈកម្មការទី៣៖ ទទួលបន្ទុកការងាររៀបចំផែនការថវិកា និងកិច្ចការរដ្ឋបាលសម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយ មានប្រធាន១រូប អនុប្រធាន២រូបទៅ៣រូប (អនុប្រធានទី១ អនុប្រធានទី២ និងអនុប្រធានទី៣) និងសមាជិក សមាជិកាមួយចំនួន មកពីអគ្គនាយកដ្ឋាន នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។

គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសម្រាប់វិស័យអប់រំ ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ

ជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអង្គការដៃគូពាក់ព័ន្ធ។ គណៈកម្មការនេះ ត្រូវបំពេញតួនាទី និងទទួលខុសត្រូវចំពោះភារកិច្ចរបស់ខ្លួន (ដូចមានចែងលម្អិតក្នុងឧបសម្ព័ន្ធ២)។

## ៤.១ តួនាទី និងភារកិច្ច គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសម្រាប់វិស័យអប់រំ

គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយក្រសួងអប់រំ យុវជន និងកីឡាមានភារកិច្ចដូចខាងក្រោម៖

- ត្រៀមបង្ការ និងកាត់បន្ថយគ្រោះថ្នាក់មុនពេលមានគ្រោះមហន្តរាយ
- ត្រៀមរៀបចំផែនការឆ្លើយតបមុនពេលកើតមានគ្រោះមហន្តរាយ
- ឆ្លើយតប សង្គ្រោះបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយ
- ស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ។

## ៤.២ តួនាទី និងភារកិច្ច លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ

លេខាធិការដ្ឋានមានភារកិច្ចរួមជាសេនាធិការ ឱ្យយន្តការគ្រប់គ្រងគ្រោះមហន្តរាយក្រសួងអប់រំ យុវជន និងកីឡា។ លេខាធិការដ្ឋានដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលរាល់ការងារទំនាក់ទំនងទៅនឹងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីធានាបានការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំប្រកបដោយប្រសិទ្ធភាព។ លេខាធិការដ្ឋានមាន ភារកិច្ចដូចខាងក្រោម៖

- ដើរតួជាមន្ត្រីបង្គោលក្នុងការសម្របសម្រួល និងចែករំលែកព័ត៌មាននៃការងារគ្រប់គ្រងគ្រោះមហន្តរាយជាមួយអនុគណៈកម្មការទាំងបី គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងដៃគូពាក់ព័ន្ធ ក្រោមការគាំទ្ររបស់គណៈគ្រប់គ្រង

ទាំងការងារមុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ។

- កសាង និងអនុវត្តផែនការគ្រប់គ្រងគ្រោះមហន្តរាយរបស់យន្តការទាំងមូល រួមទាំងលេខាធិការដ្ឋានផ្ទាល់ ដោយសម្របសម្រួលជាមួយគ្រប់ភាគីពាក់ព័ន្ធ ដែលមាននាយកដ្ឋានពាក់ព័ន្ធ និងអង្គការដៃគូ។
- ផ្សព្វផ្សាយផែនការដល់សមាជិកសមាជិកា និងអ្នកពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ចូលរួមអនុវត្តផែនការ តាមដានត្រួតពិនិត្យ និងវាយតម្លៃការងារគ្រប់គ្រងគ្រោះមហន្តរាយ សម្រាប់វិស័យរបស់ខ្លួនជាប្រចាំជាមួយ ថ្នាក់ក្រោមជាតិ សង្គមស៊ីវិល អង្គការដៃគូពាក់ព័ន្ធនានា។
- សហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងធ្វើការទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ដើម្បីផ្តល់ព័ត៌មានគ្នាទៅវិញទៅមក និងឆ្លើយតបទាន់ពេលវេលា។
- ប្រជុំលើកបញ្ហា និងសំណើតម្រូវការថវិកា សម្រាប់គាំទ្រដល់កម្មវិធីនានាទាក់ទងលេខាធិការដ្ឋាន ក្នុងការដោះស្រាយបញ្ហាដែលកើតឡើងទាំងមុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ ឬតម្រូវការចាំបាច់ជាបន្ទាន់ផ្សេងៗ ដូចជាការត្រៀមបង្ការ ឆ្លើយតប សង្គ្រោះបន្ទាន់ ជួសជុល ឬកសាងឡើងវិញ ការខូចខាតសម្ភារៈសិក្សា អគារសិក្សាដែលរងផលប៉ះពាល់ ដោយគ្រោះមហន្តរាយ។
- ពង្រឹងទំនាក់ទំនង កិច្ចសហការ និងសុំអន្តរាគមន៍ពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយក្នុងករណីចាំបាច់ ដើម្បីចូលរួមទប់ស្កាត់ កាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយដែលកើតឡើង។
- ប្រមូលព័ត៌មាន និងបូកសរុបរបាយការណ៍ពីថ្នាក់ក្រោមជាតិ រាល់ករណីជួបបញ្ហាគ្រោះមហន្តរាយ និងបន្តចែករំលែកដល់គណៈគ្រប់គ្រងយន្តការ អនុគណៈកម្មការទាំងបី គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងដៃគូពាក់ព័ន្ធ។

**ប្រធាន និងអនុប្រធានលេខាធិការដ្ឋាន**

- មានភារកិច្ចដឹកនាំ ដើម្បីសម្រេចនូវភារកិច្ចដែលចែងខាងលើ។
- ប្រធានត្រូវចាត់តាំង ឬធ្វើប្រតិភូកម្មការងារដល់មន្ត្រីបង្គោលណាមួយនៅពេលប្រធាន អវត្តមាន។
- កោះប្រជុំប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ ឬករណីបន្ទាន់ជាមួយសមាជិកលេខាធិការដ្ឋានទាំងអស់ តំណាងអនុគណៈកម្មការទាំងបី និងអ្នកពាក់ព័ន្ធ ដើម្បីបូកសរុបផ្ទៀងផ្ទាត់ និងលើកទិសដៅបន្ត។
- កោះប្រជុំបន្ទាន់ ប្រសិនបើមានករណីគ្រោះអាសន្ន ឬគ្រោះមហន្តរាយ ជាមួយសមាជិកលេខាធិការដ្ឋានទាំងអស់ តំណាងអនុគណៈកម្មការទាំងបី និងអ្នកពាក់ព័ន្ធដើម្បីឆ្លើយតប និងស្តារឡើងវិញទាន់ពេលវេលា។

**មន្ត្រីបង្គោល និងសមាជិក លេខាធិការដ្ឋាន**

- ជាជំនួយការនៃការងារដល់ប្រធាន និងគណៈគ្រប់គ្រង ហើយបំពេញភារកិច្ចតាមការចាត់តាំង របស់ប្រធាន ឬគណៈគ្រប់គ្រង
- រៀបចំទុកដាក់ឯកសារផ្សេងៗដែលពាក់ព័ន្ធ
- រៀបចំកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗ
- ធ្វើកំណត់ហេតុឬរបាយការណ៍ប្រចាំត្រីមាសឬឆមាសនីមួយៗដើម្បីជូនប្រធានលេខាធិការដ្ឋាន និងគណៈគ្រប់គ្រងក្រសួងអប់រំ យុវជន និងកីឡា។

## ៤.៣ តួនាទី និងភារកិច្ច ទីប្រឹក្សាជាតិ

នៅក្នុងយន្តការគ្រប់គ្រងគ្រោះមហន្តរាយក្រសួងអប់រំ យុវជន និងកីឡា មានទីប្រឹក្សាជាតិមួយរូប មកពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បី៖

- គាំទ្រការងារបច្ចេកទេស និងសហការក្នុងការសម្របសម្រួលរាល់ការងារគ្រប់គ្រងជាមួយលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយក្រសួងអប់រំ យុវជន និងកីឡា។
- ផ្តល់ប្រឹក្សាយោបល់ និងទំនាក់ទំនងជាមួយអនុគណៈកម្មការបច្ចេកទេសទាំងបីនៃយន្តការ គ្រប់គ្រងគ្រោះមហន្តរាយក្រសួងអប់រំ យុវជន និងកីឡា។

- ពង្រឹងសមត្ថភាពមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ។
- ជំរុញដំណើរការអនុវត្តការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព។
- ផ្តល់ព័ត៌មានត្រឡប់ទៅគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

## ៤.៤ តួនាទី និងភារកិច្ចគណៈកម្មការបច្ចេកទេស (ឧបសម្ព័ន្ធ២)

គណៈកម្មការបច្ចេកទេសគឺជាសេនាធិការឱ្យយន្តការទាំងមូលនៃគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយក្រសួង ដើម្បីជានាបាននូវនិរន្តរភាពលើការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ព្រមទាំងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ។ អនុគណៈកម្មការទាំងបីនៃគណៈកម្មការបច្ចេកទេស មានតួនាទីនិងភារកិច្ចទទួលខុសត្រូវដូចតទៅ៖

- អនុគណៈកម្មការទី១៖ ទទួលបន្ទុកការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- អនុគណៈកម្មការទី២៖ ទទួលបន្ទុកការងារត្រៀមរៀបចំឆ្លើយតប និងការងារឆ្លើយតបគ្រោះមហន្តរាយ
- អនុគណៈកម្មការទី៣៖ ទទួលបន្ទុកការងាររៀបចំផែនការ ថវិកា និងកិច្ចការរដ្ឋបាលសម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយ។

# ៥. ផលប៉ះពាល់នៃគ្រោះមហន្តរាយលើវិស័យអប់រំ

## គ្រោះទឹកជំនន់

គ្រោះទឹកជំនន់ត្រូវបានចាត់ទុកជាមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិធំជាងគេ ដែលបង្កការប៉ះពាល់ដល់វិស័យជាច្រើន រួមមាន សេដ្ឋកិច្ច សង្គម កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ជីវភាពរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ។ គ្រោះទឹកជំនន់ឆ្នាំ២០១៣ និងឆ្នាំ២០១៨ ថ្មីៗនេះ ត្រូវបានចាត់ទុកជាគ្រោះទឹកជំនន់ធំជាងគេក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ដែលបណ្តាលឱ្យបាត់បង់អាយុជីវិតមនុស្ស រាប់រយនាក់ សម្លាប់សត្វពាហនៈរាប់ពាន់ក្បាល ខូចខាតផលដំណាំរាប់ម៉ឺនហិកតា។ ជាក់ស្តែង ក្នុងគ្រោះទឹកជំនន់ឆ្នាំ២០១៣ សាលារៀនចំនួន១២៨០ កន្លែង ត្រូវបានទទួលរងផលប៉ះពាល់ ក្នុងនោះមានសាលាយ៉ាងតិចចំនួន១៥៥កន្លែង ត្រូវបានផ្អាកដំណើរការពី១ ដល់៥សប្តាហ៍ បណ្តាលឱ្យកុមារយ៉ាងតិច៥ម៉ឺននាក់ ខកខានមិនបានចូលរៀននៅដើមឆ្នាំសិក្សា២០១៣-២០១៤[៤] ដែលធ្វើឱ្យការរៀន និងបង្រៀនមិនទាន់តាមកម្មវិធីសិក្សា។ ការវាយតម្លៃលើការបាត់បង់ និងខូចខាតលើវិស័យអប់រំ ដោយសារគ្រោះទឹកជំនន់នៅឆ្នាំ២០១៣ កន្លងមកនេះ គិតជាទឹកប្រាក់អស់ប្រមាណជាង១៥លានដុល្លារ។ ចំនួនសាលារៀនដែលស្ថិតនៅតំបន់ភូមិសាស្ត្រប្រឈមនឹងបញ្ហាគ្រោះទឹកជំនន់ច្រើនជាងគេនៅឆ្នាំ២០១៨ មានដូចជា ខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង កំពង់ស្ពឺ កោះកុង កំពត បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ។

## ខ្យល់ព្យុះ

ជាញឹកញាប់ យើងតែងសង្កេតឃើញខ្យល់ព្យុះកើតឡើងនៅដើមរដូវវស្សា។ ខ្យល់ព្យុះមានទំនាក់ទំនងគ្នាជាមួយនឹងទឹកជំនន់។ ខ្យល់ព្យុះត្រូពិចជាមុខសញ្ញាគ្រោះថ្នាក់បែបឧតុនិយមដែលបង្កការគំរាមកំហែងខ្លាំងនៅតំបន់អាស៊ីខាងកើត និងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ជាមធ្យមក្នុងមួយឆ្នាំ ខ្យល់ព្យុះត្រូពិចអាចកើតមានឡើងរហូតដល់២៧ដង បង្កឱ្យមានផលប៉ះពាល់ក្នុងតំបន់មួយចំនួន។ ខ្យល់ព្យុះ និងវិសម្ពាធត្រូពិចខ្លះឆ្លងកាត់តំបន់ឥណ្ឌូចិន បានបង្កឱ្យមានភ្លៀងធ្លាក់ខ្លាំងនិងបង្កឱ្យមានទឹកជំនន់នៅក្នុងប្រទេសកម្ពុជានាពេលកន្លងមក។ ថ្វីត្បិតតែវិសាលភាពនៃ

៤.របាយការណ៍ អង្គការ UNDP ខែមេសា ឆ្នាំ២០១៤ ( Post-flood early recovery need assessment Report) ទំព័រទី ៣៩

ខ្យល់ព្យុះនៅប្រទេសកម្ពុជា មិនទាន់មានលក្ខណៈរាលដាលធំធេងដូចគ្រោះទឹកជំនន់ ប៉ុន្តែកម្រិតនៃផលប៉ះពាល់ និងរងគ្រោះ គឺធ្ងន់ធ្ងរខ្លាំងក្លា។ ខ្យល់ព្យុះបានបង្កការប៉ះពាល់ និងខូចខាតហេដ្ឋារចនាសម្ព័ន្ធសាធារណៈ អគារ សាលារៀន ផ្ទះសំបែង ផលដំណាំ បង្ករបួសស្នាម និងបណ្តាលឱ្យបាត់បង់ជីវិតមនុស្ស សត្វ ទៀតផង។ តួយ៉ាងព្យុះ កេតសាណា នៅឆ្នាំ២០០៩ បណ្តាលឱ្យមនុស្ស៤៣នាក់បានស្លាប់ ៦៧នាក់រងរបួសធ្ងន់ និងខូចខាតផ្ទះសំបែង របរចិញ្ចឹមជីវិត ចំនួន៤៩.០០០គ្រួសារ ស្មើនឹង១៨០.០០០នាក់ ឬ១.៤ភាគរយ នៃប្រជាជនសរុបទូទាំងប្រទេសកម្ពុជា[៥]។ នៅក្នុងឆ្នាំ២០១៨ ខ្យល់កន្ត្រាក់នៅកម្ពុជាបានធ្វើឱ្យខូចខាតផ្ទះចំនួន ២.៦៩៦ខ្នងសាលារៀនចំនួន១៨កន្លែង[៦]។

## រាំងស្ងួត

គ្រោះរាំងស្ងួតនៅប្រទេសកម្ពុជា ប៉ះពាល់ដោយផ្ទាល់ដល់វិស័យកសិកម្ម ហើយវាក៏បានជះឥទ្ធិពលដល់វិស័យដទៃទៀត ដូចជាធ្វើឱ្យមានបញ្ហាអសន្តិសុខស្បៀង បញ្ហាសុខភាព និងបញ្ហាសង្គម(ការធ្វើចំណាកស្រុក និងអំពើហិង្សាក្នុងគ្រួសារ) ហើយបានជះឥទ្ធិពលអាក្រក់ដល់វិស័យអប់រំផងដែរ។ ជាក់ស្តែងកុមារត្រូវបានឪពុកម្តាយបង្ខំឱ្យឈប់រៀនដើម្បីស្វែងរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ។ យោងតាមរបាយការណ៍អង្គការទិន្នន័យអំពីការអភិវឌ្ឍ គ្រោះរាំងស្ងួតនៅកម្ពុជា(ឆ្នាំ២០១៦) បណ្តាលឱ្យប្រជាជន២.៥ លាននាក់ រងផលប៉ះពាល់ផ្ទាល់ពីគ្រោះរាំងស្ងួត[៧]។

## គ្រោះអាសន្នផ្សេងៗ

ទន្ទឹមនឹង បញ្ហាទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ និងគ្រោះរាំងស្ងួត ក៏មានពាក់ព័ន្ធផងដែរទៅនឹងការប្រែប្រួលអាកាសធាតុ។ នៅប្រទេសកម្ពុជា ការព្យាករណ៍បានឱ្យដឹងថា បរិមាណទឹកភ្លៀងនៅរដូវវស្សា មានការកើនឡើងនៅចន្លោះពី៣% ទៅ១៤% (RGC 2013 និង USAID 2013)។ ដោយសារការប្រែប្រួលអាកាសធាតុ ធ្វើឱ្យសំណើមកាន់តែមានកម្រិតកើនឡើងខ្ពស់នៅរដូវវស្សា និងសីតុណ្ហភាពកាន់តែកើនឡើងបន្តិចម្តងៗនៅរដូវប្រាំងជារៀងរាល់ឆ្នាំ។ បញ្ហាទាំងនេះជះឥទ្ធិពលទៅលើបម្រែបម្រួលនៃទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ និងគ្រោះរាំងស្ងួត ដែលកើនឡើងកាន់តែញឹកញាប់ នៅក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។

ក្រៅពីគ្រោះមហន្តរាយទាំងនេះ កម្ពុជា ក៏ប្រឈមទៅនឹងគ្រោះអាសន្នផ្សេងៗ ដូចជា

៥. របាយការណ៍គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (2009 Post-Ketsana Disaster need assessment report March, 2010) ទំព័រទី ១៥
៦. របាយការណ៍គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គិតត្រឹមខែកក្កដា ឆ្នាំ២០១៨
៧. របាយការណ៍អង្គការទិន្នន័យអំពីការអភិវឌ្ឍ គិតត្រឹមខែឧសភា ឆ្នាំ២០១៦

រន្ទះបាញ់ អគ្គីភ័យ និងជំងឺឆ្លងរាតត្បាតផ្សេងៗដូចជាជំងឺផ្តាសាយបក្សី និងគ្រុនឈាមជាដើម។

**កត្តាប្រឈមចំពោះគ្រោះមហន្តរាយ**

| ផ្នែក | ទឹកជំនន់ | ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ | គ្រោះរាំងស្ងួត |
|---|---|---|---|
| ការចូលរួម | -ការចូលរួមគ្រប់ភាគីពាក់ព័ន្ធនៅមានកម្រិត<br>- ឆ្លើយតបមិនទាន់គ្រប់ជ្រុងជ្រោយ | -ការចូលរួមគ្រប់ភាគីពាក់ព័ន្ធនៅមានកម្រិត<br>-ឆ្លើយតបមិនទាន់គ្រប់ជ្រុងជ្រោយ | -ការចូលរួមគ្រប់ភាគីពាក់ព័ន្ធនៅមានកម្រិត<br>-ឆ្លើយតបមិនទាន់គ្រប់ជ្រុងជ្រោយ |
| ធនធាន | -កង្វះថវិកា សម្ភារៈ និងអ្នកជំនាញ | -កង្វះថវិកា សម្ភារៈ និងអ្នកជំនាញ | -កង្វះថវិកា សម្ភារៈ និងអ្នកជំនាញ |
| ការប៉ាន់ប្រមាណ | -ប៉ះពាល់ធ្ងន់ធ្ងរ<br>-ការកំណត់មុខសញ្ញាគ្រោះថ្នាក់នៅតំបន់រងគ្រោះមិនទាន់ច្បាស់លាស់នៅឡើយ | -ប៉ះពាល់ធ្ងន់ធ្ងរ<br>-ការកំណត់មុខសញ្ញាគ្រោះថ្នាក់នៅតំបន់រងគ្រោះមិនទាន់ច្បាស់លាស់នៅឡើយ | -ប៉ះពាល់ធ្ងន់ធ្ងរ<br>-ការកំណត់មុខសញ្ញាគ្រោះថ្នាក់នៅតំបន់រងគ្រោះមិនទាន់ច្បាស់លាស់នៅឡើយ |
| យុទ្ធសាស្ត្រឆ្លើយតប | -កង្វះទំនាក់ទំនងរវាងថ្នាក់ជាតិ និងក្រោមជាតិដែលធ្វើឱ្យមានការយឺតយ៉ាវ | -កង្វះទំនាក់ទំនងរវាងថ្នាក់ជាតិ និងក្រោមជាតិ ដែលធ្វើឱ្យមានការយឺតយ៉ាវ | -កង្វះទំនាក់ទំនងរវាងថ្នាក់ជាតិ និងក្រោមជាតិដែលធ្វើឱ្យមានការយឺតយ៉ាវ |
| ការតាមដាន | -ខ្វះប្រព័ន្ធផ្តល់ព័ត៌មានគ្រប់តំបន់គោលដៅ (១២៩៤)<br>-ខ្វះរបាយការណ៍ និងយឺតយ៉ាវ | -ខ្វះប្រព័ន្ធផ្តល់ព័ត៌មានគ្រប់តំបន់គោលដៅ<br>-ខ្វះរបាយការណ៍ និងយឺតយ៉ាវ | -ខ្វះប្រព័ន្ធផ្តល់ព័ត៌មានគ្រប់តំបន់គោលដៅ<br>-ខ្វះរបាយការណ៍ និងយឺតយ៉ាវ |

| ផ្នែក | ទឹកជំនន់ | ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ | គ្រោះរាំងស្ងួត |
|---|---|---|---|
| ការវាយតម្លៃ | -មិនទាន់សុក្រិត<br>-មិនទាន់ឯកភាព | -មិនទាន់សុក្រិត<br>-មិនទាន់ឯកភាព | -មិនទាន់សុក្រិត<br>-មិនទាន់ឯកភាព |
| ការចូលរៀន និងបរិស្ថានសិក្សា | -វិសមភាពនៃការចុះឈ្មោះចូលរៀនរវាងតំបន់រងគ្រោះទឹកជំនន់( ទឹកជំនន់តំបន់ភ្នំ) និងតំបន់មិនរងគ្រោះទឹកជំនន់<br>-បរិយាកាសសិក្សាពុំមានសុវត្ថិភាព មិនធានាដល់ការសិក្សារបស់សិស្ស<br>-ដំងឺរាតត្បាតផ្សេងៗ បង្ករបួសស្នាម និងបណ្តាលឱ្យបាត់បង់ជីវិតមនុស្ស<br>-បង្កន់អនាម័យស្ទះ កង្វក់<br>-ប៉ះពាល់សុខភាព អនាម័យ អាយុជីវិតកុមារ<br>-ខូចខាតសម្ភារៈសិក្សា និងឧករណ៍សាលារៀន មាន តុ ទូ កៅអី សៀវភៅសិក្សាគោល...<br>-ខូចខាតអគារសិក្សា (ប្រេះស្រាំ បាក់ស្រុតលិចទឹក)<br>-ខូចខាតទីធ្លាបរិស្ថានសាលា និងទីលានកីឡា ស្លួនជីវចម្រុះ សួនកុមារត្រូវបាក់បែក | -បរិយាកាសសិក្សាពុំមានសុវត្ថិភាព មិនធានាដល់ការសិក្សារបស់សិស្ស<br>-បង្ករបួសស្នាម និងអាចបណ្តាលឱ្យបាត់បង់ជីវិតកុមារ<br>-ខូចខាតសម្ភារឧករណ៍សាលារៀន មានតុ ទូ កៅអី សៀវភៅសិក្សាគោល...<br>-ខូចខាតអគារសិក្សា (ប្រេះស្រាំ របើកដំបូលបាក់អគារសិក្សា)<br>-ខូចខាតទីធ្លាបរិស្ថានសាលា (បាក់រលំដើមឈើ) | -បរិយាកាសសិក្សាពុំមានផាសុកភាព ដល់ការសិក្សារបស់សិស្ស<br>-ដំងឺរាតត្បាតផ្សេងៗ បណ្តាលឱ្យបាត់បង់ជីវិតកុមារ<br>-កុមារកង្វះអាហារូបត្ថម្ភ<br>-ប៉ះពាល់ផ្នែកសុខភាព និងអនាម័យសិស្ស (កង្វះទឹក កង្វះជាតិស្ករ)<br>-បង្គន់អនាម័យមិនដំណើរការ (កង្វះទឹក)<br>-ខូចខាតអគារសិក្សា (ប្រេះ) |

| ផ្នែក | ទឹកជំនន់ | ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ | គ្រោះរាំងស្ងួត |
|---|---|---|---|
| ការរៀន និងបង្រៀន | -ផ្អាកការសិក្សាដោយសារកម្រិតកម្ពស់ទឹកជំនន់ឡើងខ្លាំង (លិចសាលា លិចភូមិ)<br>-តំបន់រងគ្រោះដោយទឹកជំនន់មិនអាចអនុវត្តកម្មវិធីសិក្សាតាមការកំណត់របស់ក្រសួង<br>-សិស្សអវត្តមាន និងបោះបង់ការសិក្សា<br>-គ្រូ-សិស្សមានការភ័យខ្លាច និងព្រួយបារម្ភអំពីសុវត្ថិភាព | -ផ្អាកការសិក្សាដោយសារខ្យល់ព្យុះ ខ្យល់កន្ត្រាក់ (របើកដំបូងសាលា)<br>-តំបន់រងគ្រោះដោយខ្យល់ព្យុះ ខ្យល់កន្ត្រាក់មិនអាចអនុវត្តកម្មវិធីសិក្សាតាមការកំណត់របស់ក្រសួង<br>-សិស្សអវត្តមាន និងបោះបង់ការសិក្សា<br>-គ្រូ-សិស្សមានការភ័យខ្លាច និងព្រួយបារម្ភអំពីសុវត្ថិភាព | -ផ្អាកការសិក្សាដោយសារកម្តៅឡើងខ្លាំង<br>-តំបន់រងគ្រោះរាំងស្ងួតមិនអាចអនុវត្តកម្មវិធីសិក្សាតាមការកំណត់របស់ក្រសួង<br>-សិស្សអវត្តមាន និងបោះបង់ការសិក្សា<br>-មាតាបិតាសិស្សមានការព្រួយបារម្ភអំពីសុវត្ថិភាព និងសុខភាពរបស់កុមារ |
| គ្រូបង្រៀន និងបុគ្គលិកអប់រំ | -រំខានដល់ការបង្រៀន និងរៀន<br>-ចំណេះដឹងគ្រូពាក់ព័ន្ធនឹងគ្រោះទឹកជំនន់នៅមានកម្រិត<br>-យន្តការគាំទ្រ និងត្រួតពិនិត្យសម្រាប់គ្រូបង្រៀន និងបុគ្គលិកអប់រំក្នុង កំឡុងពេលគ្រោះទឹកជំនន់នៅមានកម្រិត | -រំខានដល់ការបង្រៀន និងរៀន<br>-ចំណេះដឹងគ្រូពាក់ព័ន្ធនឹងខ្យល់ព្យុះ ខ្យល់កន្ត្រាក់នៅមានកម្រិត<br>-យន្តការគាំទ្រ និងត្រួតពិនិត្យសម្រាប់គ្រូបង្រៀន និងបុគ្គលិកអប់រំក្នុងកំឡុងពេលខ្យល់ព្យុះ ខ្យល់កន្ត្រាក់នៅមានកម្រិត | -រំខានដល់ការបង្រៀន និងរៀន<br>-ចំណេះដឹងគ្រូពាក់ព័ន្ធនឹងគ្រោះរាំងស្ងួតនៅមានកម្រិត<br>-យន្តការគាំទ្រ និងត្រួតពិនិត្យសម្រាប់គ្រូបង្រៀន និងបុគ្គលិកអប់រំក្នុងកំឡុងពេលគ្រោះរាំងស្ងួតនៅមានកម្រិត |

| ផ្នែក | ទឹកជំនន់ | ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ | គ្រោះរាំងស្ងួត |
|---|---|---|---|
| គោលនយោបាយវិស័យអប់រំ | -ការបង្កើតច្បាប់ និងគោលនយោបាយឆ្លើយតបគ្រោះមហន្តរាយក្នុងវិស័យអប់រំពុំទាន់រៀបចំជាផ្លូវការ<br>- ផែនការ និងការអនុវត្តការគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំនៅមានកម្រិត | -ការបង្កើតច្បាប់ និងគោលនយោបាយឆ្លើយតបគ្រោះមហន្តរាយក្នុងវិស័យអប់រំពុំទាន់រៀបចំជាផ្លូវការ<br>-ផែនការ និងការអនុវត្តការគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំនៅមានកម្រិត | -ការបង្កើតច្បាប់ និងគោលនយោបាយឆ្លើយតបគ្រោះមហន្តរាយក្នុងវិស័យអប់រំពុំទាន់រៀបចំជាផ្លូវការ<br>- ផែនការ និងការអនុវត្តការគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំនៅមានកម្រិត |

## ៦. សេណារីយ៉ូ និងការតាមដានហានិភ័យគ្រោះមហន្តរាយ

យោងតាមប្រវត្តិគ្រោះមហន្តរាយនៅកម្ពុជាដែលកើតមានជាញឹកញាប់ គឺគ្រោះទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ និងគ្រោះរាំងស្ងួត។ ដូចនេះ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់វិស័យអប់រំ គួរផ្តោតលើមុខសញ្ញាគ្រោះថ្នាក់ខាងលើ ដើម្បីពង្រឹងសមត្ថភាពត្រៀមបម្រុង និងឆ្លើយតប។ ខ្យល់ព្យុះ និងខ្យល់កន្ត្រាក់ មានសណ្ឋានខុសគ្នា ប៉ុន្តែក្នុងការកសាងផែនការនេះ ក្រុមការងារសម្រេចដាក់មុខសញ្ញាគ្រោះថ្នាក់ទាំងពីរនេះ ទៅក្នុងជំពូកតែមួយសម្រាប់ផលប៉ះពាល់កម្រិតជាតិ។ នៅក្នុងផ្នែកនេះ បង្ហាញពីការប៉ាន់ប្រមាណហានិភ័យ និងផលប៉ះពាល់ក្នុងវិស័យអប់រំ ទាំងផ្នែកអប់រំកុមារតូច បឋមសិក្សា និងមធ្យមសិក្សា។ ទន្ទឹមនឹងនេះ ក៏នៅមានគ្រោះមហន្តរាយផ្សេងៗទៀត ដូចជាបញ្ហាសង្គម ជំងឺរាតត្បាត និងបញ្ហាចំណាកស្រុកទ្រង់ទ្រាយធំ ដែលអាចកើតមានឡើង ហើយគួរតែឆ្លើយតបតាមគោលការណ៍ និងយុទ្ធសាស្ត្រ ដែលបានបង្ហាញក្នុងផែនការនេះ។

### កម្រិតសេណារីយ៉ូ

ក្នុងសិក្ខាសាលាធ្វើចំណាត់ថ្នាក់កម្រិតហានិភ័យនៃគ្រោះមហន្តរាយ នៅខែកក្កដា ឆ្នាំ២០១៨

ដែលមានការចូលរួមពីក្រុមការងារ លេខាធិការដ្ឋាន និងក្រុមការងារយន្តការគ្រប់គ្រងគ្រោះមហន្តរាយក្រសួង មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និង អង្គការដៃគូ គ្រោះទឹកជំនន់ ត្រូវបានធ្វើចំណាត់ថ្នាក់ខ្ពស់ ដែលទាមទារឱ្យក្រសួងអប់រំធ្វើផែនការលម្អិតទៅលើមុខសញ្ញាគ្រោះមហន្តរាយនេះ។

ខាងក្រោមគឺជាចំណាត់ថ្នាក់មុខសញ្ញាគ្រោះមហន្តរាយៈ




ចំណាត់ថ្នាក់ហានិភ័យនេះ ត្រូវពិនិត្យឡើងវិញរៀងរាល់៦ខែម្តង ដើម្បីជានាការត្រៀមរៀបចំមុនគ្រោះមហន្តរាយមានប្រសិទ្ធភាពខ្ពស់។ ក្នុងឆ្នាំ២០១៩ ហានិភ័យគ្រោះមហន្តរាយបានឱ្យចំណាត់ថ្នាក់ខ្ពស់ទៅលើគ្រោះរាំងស្ងួត ដែលបង្កដោយបាតុភូតិ El Ninoដែលនឹងមានការកើនកំដៅខ្ពស់នៅតាមបណ្តាខេត្តមួយចំនួន។

## ការតាមដានហានិភ័យគ្រោះមហន្តរាយ

ដើម្បីតាមដានការកើនឡើងនូវហានិភ័យគ្រោះមហន្តរាយ ប្រភពព័ត៌មានខាងក្រោមត្រូវបានកំណត់ឡើងសម្រាប់ធ្វើជាយន្តការក្នុងការតាមដានហានិភ័យគ្រោះមហន្តរាយ៖

| ហានិភ័យ | ប្រភព/សូចនាករព័ត៌មាន | អ្នកទទួលខុសត្រូវ | កង្វះ/ប្រឈម | |
|---|---|---|---|---|
| | | | ប្រឈម | ដំណោះស្រាយ |
| ទឹកជំនន់ | • ឧតុនិយម (www.cambodiameteo.com)<br>• ពេលវេលារដូវកាល(ខែ៧ ទៅខែ១០)<br>• តាមទម្លាប់ចំណាំទៅសត្វនិងរុក្ខជាតិ<br>• តាមរយៈទូរសព្ទ័អ្នកនៅផ្នែកខាងលើប្រភពទឹក<br>• ប្រព័ន្ធ១២៩៤<br>• តាមការប្រកាសកម្ពស់ទឹក<br>• ព័ត៌មានពីមជ្ឈដ្ឋានជុំវិញ<br>• វិទ្យុ ទូរទស្សន៍ និងសារព័ត៌មានបណ្ដាញសង្គម<br>• ឧបករណ៍វាស់កម្ពស់ទឹក<br>• គេហទំព័រគណៈកម្មការទន្លេមេគង្គ ffw.mrcmekong.org **<br>• ការព្យាករណ៍ពីកម្រិតទឹកភ្លៀងនៅប្រទេសឡាវ និងវៀតណាម | • គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់ថ្នាក់ជាតិនិងក្រោមជាតិ<br>• មន្ត្រីអប់រំស្រុករហូតដល់មន្ទីរអយក (មន្ត្រីបង្គោល)<br>• ក្រសួងធនធានទឹកនិងឧតុនិយម | • មិនទាន់មានទំនាក់ទំនងជាមួយមន្ត្រីឧតុនិយមខេត្ត<br>• ខ្វះប្រព័ន្ធ១២៩៤<br>• ខ្វះខាតការផ្សព្វផ្សាយទូទៅ<br>• ខ្វះខាតឧបករណ៍បច្ចេកទេស<br>• ខ្វះខាតមន្ត្រីជំនាញ<br>• ស្ថានភាពភូមិសាស្ត្រតាមតំបន់<br>• គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់មិនទាន់បានបំពេញភារកិច្ចបានគ្រប់ជ្រុងជ្រោយ<br>• ថវិកាត្រៀមនិងឆ្លើយតបមិនទាន់មានគ្រប់គ្រាន់<br>• ការយល់ដឹងនិងការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិត | • ត្រូវមានទំនាក់ទំនងជាមួយមន្ត្រីឧតុនិយម<br>• ពង្រីកបន្ថែមប្រព័ន្ធ១២៩៤<br>• រៀបចំផែនការត្រៀមបម្រុង<br>• រៀបចំនិងតែងតាំងមន្ត្រីបង្គោលឱ្យច្បាស់លាស់<br>• កំណត់និងស្វែងដៃគូអភិវឌ្ឍន៍<br>• រៀបចំឱ្យមានថវិកាជាតិសម្រាប់ត្រៀមបម្រុងនិងឆ្លើយតបឱ្យច្បាស់លាស់ |

| ហានិភ័យ | ប្រភព/សូចនាករព័ត៌មាន | អ្នកទទួលខុសត្រូវ | កត្តាប្រឈម | |
|---|---|---|---|---|
| | | | ប្រឈម | ដំណោះស្រាយ |
| ខ្យល់ព្យុះ | • ឧតុនិយម ( www.cambodiameteo.com)<br>• មេឃងងឹតពពកខ្មៅច្រើន<br>• សីតុណ្ហភាពក្តៅខ្លាំងខុសពីថ្ងៃធម្មតា<br>• ល្បឿនខ្យល់<br>• ការប្រកាសព័ត៌មាន<br>• វាស់កម្រិតទឹកភ្លៀង | • គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់ថ្នាក់ជាតិនិងក្រោមជាតិ<br>• មន្ត្រីអប់រំស្រុករហូតដល់មន្ទីរអយក(មន្ត្រីបង្គោល)<br>• ក្រសួងធនធានទឹកនិងឧតុនិយម | • ខូចខាតអគារសិក្សា | • រៀបចំផែនការត្រៀមបម្រុង<br>• ត្រូវមានទំនាក់ទំនងជាមួយមន្ត្រីឧតុនិយម<br>• ពង្រីកបន្ថែមប្រព័ន្ធ ១២៩៤<br>• រៀបចំនិងតែងតាំងមន្ត្រីបង្គោលឱ្យច្បាស់លាស់<br>• កំណត់និងស្វែងដៃគូអភិវឌ្ឍន៍<br>• រៀបចំឱ្យមានថវិកាជាតិសម្រាប់ត្រៀមបម្រុងនិងឆ្លើយតបឱ្យច្បាស់លាស់ |

| ហានិភ័យ | ប្រភព/សូចនាករព័ត៌មាន | អ្នកទទួលខុសត្រូវ | កត្តាប្រឈម | |
|---|---|---|---|---|
| | | | ប្រឈម | ដំណោះស្រាយ |
| រាំងស្ងួត | • ឧតុនិយម ( www.cambodiameteo.com)<br>• ពេលវេលារដូវកាល (ខែ២ ដល់ខែ៥)<br>• អាកាសធាតុការប្រកាសព័ត៌មាន<br>• កម្រិតទឹកក្នុងអណ្តូង/ទឹកក្រោមដី/ទឹកស្រះ/ទន្លេ<br>• សាលារៀនគ្មានទឹកប្រើប្រាស់<br>• ចំនួនកុមារអវត្តមានដោយជំងឺលើសពី៣០%ទូទាំងប្រទេស | • គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់ថ្នាក់ជាតិនិងក្រោមជាតិ<br>• មន្ត្រីអប់រំស្រុករហូតដល់មន្ទីរអេយក (មន្ត្រីបង្គោល)<br>• ក្រសួងធនធានទឹកនិងឧតុនិយម | • ខ្វះទឹកប្រើប្រាស់<br>• ប៉ះពាល់ម៉ោងសិក្សារបស់សិស្ស | • មានអាងស្តុកទឹកតាមសាលា<br>• មានធុងស្តុកទឹកតាមថ្នាក់<br>• រៀបប្រព័ន្ធទឹក(ជីកអណ្តូង)<br>• រៀបចំផែនការត្រៀមបម្រុង<br>• ត្រូវមានទំនាក់ទំនងជាមួយមន្ត្រីឧតុនិយម<br>• ពង្រីកបន្ថែមប្រព័ន្ធ១២៩៤<br>• រៀបចំនិងតែងតាំងមន្ត្រីបង្គោលឱ្យច្បាស់លាស់<br>• កំណត់និងស្វែងដៃគូអភិវឌ្ឍន៍<br>• រៀបចំឱ្យមានថវិកាជាតិសម្រាប់ត្រៀមបម្រុងនិងឆ្លើយតប ឱ្យច្បាស់លាស់ |
| រន្ទះបាញ់ | • កម្រិតទឹកភ្លៀង<br>• ឧតុនិយម<br>• មេឃដុំពពកខ្មៅច្រើន<br>• | • គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់ថ្នាក់ជាតិនិងក្រោមជាតិ<br>• មន្ត្រីអប់រំស្រុករហូតដល់មន្ទីរអេយក (មន្ត្រីបង្គោល)<br>• ក្រសួងធនធានទឹកនិងឧតុនិយម | • មិនអាចព្យាករណ៍បានច្បាស់លាស់ | • រៀបចំផែនការត្រៀមបម្រុង<br>• ត្រូវមានទំនាក់ទំនងជាមួយមន្ត្រីឧតុនិយម<br>• ពង្រីកបន្ថែមប្រព័ន្ធ១២៩៤<br>• រៀបចំផែនការត្រៀមបម្រុង<br>• រៀបចំនិងតែងតាំងមន្ត្រីបង្គោលឱ្យច្បាស់លាស់<br>• កំណត់និងស្វែងរកដៃគូអភិវឌ្ឍន៍<br>• រៀបចំឱ្យមានថវិកាជាតិសម្រាប់ត្រៀមបម្រុងនិងឆ្លើយតបឱ្យច្បាស់លាស់ |

* * ចំពោះកម្រិតនៃការប្រកាសគ្រោះអាសន្នសម្រាប់គ្រោះទឹកជំនន់ ទិន្នន័យកម្ពស់ទឹកត្រូវបានព្យាករណ៍ទៅតាមស្ថានីយជលសាស្ត្រ ចំនួន៧ ដែលស្ថិតនៅតាមដងទន្លេមេគង្គ និងទន្លេសាប។

| **ឈ្មោះស្ថានីយជលសាស្ត្រ** | **កម្រិតប្រកាសអាសន្ន** (វាស់កំពស់ទឹកគិតជាម៉ែត្រ) | | | | |
|---|---|---|---|---|---|
| | កម្រិតមិនមានភាពអាសន្ន និង និមិត្តសញ្ញា | កម្រិតប្រកាសភាពអាសន្ន និង និមិត្តសញ្ញា | | **កម្រិតទឹកជំនន់ និង និមិត្តសញ្ញា** | |
| ទន្លេមេគង្គ ស្ទឹងត្រែង | ↓ ↑ | ១០.៧០ | ↓ ↑ | ១២.០០ | ↓ ↑ |
| ទន្លេមេគង្គ ក្រចេះ | | ២២.០០ | | ២៣.០០ | |
| ទន្លេមេគង្គ កំពង់ចាម | | ១៥.២០ | | ១៦.២០ | |
| ទន្លេចតុមុខ ភ្នំពេញ | | ១០.៥០ | | ១២.០០ | |
| ទន្លេសាប កំពង់ផែភ្នំពេញ | | ៩.៥០ | | ១១.០០ | |
| ទន្លេបាសាក់ កោះខែល | | ៧.២០ | | ៧.៩០ | |
| ទន្លេមេគង្គ អ្នកលឿង | | ៧.៥០ | | ៨.០០ | |
| ទន្លេសាប ព្រែកក្តាម | | ៩.៥០ | | ១០.០០ | |

## ៧. ប្រព័ន្ធព័ត៌មានឱ្យដឹងជាមុន១២៩៤

ប្រព័ន្ធព័ត៌មានឱ្យដឹងជាមុន មានសារៈសំខាន់ណាស់ឱ្យយើងដឹងពីប្រតិបត្តិការដែលកើតឡើង និងត្រៀមលក្ខណៈបានគ្រប់គ្រាន់ រួមទាំងពេលវេលានិងធនធាន និងវិធានការនានាក្នុងការឆ្លើយតបក្នុងគ្រាអាសន្ន ឬគ្រោះមហន្តរាយ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ដែលបានកើតមានឡើងនៅកម្រិតអប្បបរមាបំផុត។ ការផ្តល់ដំណឹងជាមុន គឺរួមមាន ក្តារខៀនព័ត៌មាន ជួងសញ្ញា និងទូរស័ព្ទ ។

អនុគណៈកម្មាការទី១ និងលេខាធិការដ្ឋាន ដើរតួយ៉ាងសំខាន់ក្នុងការតាមដាននូវព័ត៌មាននានា ទាក់ទងនឹងការព្យាករណ៍ ឧតុនិយម និងអាកាសធាតុតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ដូចជាទូរទស្សន៍ វិទ្យុ កាសែត ប្រព័ន្ធទូរស័ព្ទ ដើម្បីដឹងពីព័ត៌មាន ទឹកជំនន់ ខ្យល់ព្យុះ កម្រិតទឹកភ្លៀង និងការប្រែប្រួលអាកាសធាតុផ្សេងៗ ។

ដើម្បីដឹងព័ត៌មានស្តីពីគ្រោះមហន្តរាយ តាមរយៈប្រព័ន្ធទូរស័ព្ទដៃ១២៩៤ (ប្រព័ន្ធប្រកាសឱ្យដឹងជាមុន) យើងត្រូវធ្វើការចុះឈ្មោះក្នុងប្រព័ន្ធនេះ ជាមុនតាមវិធីដូចខាងក្រោម៖




រាល់ព័ត៌មានស្តីពីផលប៉ះពាល់ គ្រោះអាសន្ន ឬការប្រកាសព័ត៌មានឱ្យដឹងមុន ត្រូវធ្វើបច្ចុប្បន្នកម្មតាមរយៈ Telegram ឈ្មោះ "មន្ត្រីបង្គោលគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី ខេត្ត" និងរាយការណ៍ទៅកាន់មន្ត្រីបង្គោលរបស់យន្តការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់ជាន់ថ្នាក់។

ទម្រង់របាយការណ៍ ដូចមាននៅក្នុងឧបសម្ព័ន្ធ នឹងត្រូវប្រើប្រាស់សម្រាប់រាយការណ៍ផលប៉ះពាល់គ្រោះមហន្តរាយក្នុងវិស័យអប់រំ។

## ៨. សកម្មភាពត្រៀមបង្ការអប្បបរមា និងកាត់បន្ថយហានិភ័យមុនគ្រោះមហន្តរាយ

| សកម្មភាពត្រៀមបង្ការ និងកាត់បន្ថយហានិភ័យមុនគ្រោះមហន្តរាយ | ផែនការគ្រោងអនុវត្ត ( Plan to implement ) | អ្នកទទួលខុសត្រូវដឹកនាំ | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| ប្រជុំពិនិត្យតាមដានកម្រិតហានិភ័យដែលអាចកើតឡើង | ខែមីនា ឧសភា | លេខាធិការដ្ឋាន | អនុគណៈកម្មការទី ១<br>អនុគណៈកម្មការទី ២<br>អនុគណៈកម្មការទី ៣<br>អង្គការដៃគូ |
| ការប្រជុំសម្រាប់សហប្រតិបត្តិការរវាងស្ថាប័នពាក់ពន្ធ័ ប្រចាំខែ ជាទៀងទាត់ | រាល់ខែ | លេខាធិការដ្ឋាន | អនុគណៈកម្មាការទី១ ទី២ ទី៣ និងអង្គការដៃគូ |
| សម្របសម្រួលចេញសេចក្ដីណែនាំ ដល់សាលារៀនដើម្បីធ្វើការប៉ាន់ប្រមាណមុខសញ្ញាគ្រោះថ្នាក់ សមត្ថភាព និងភាពងាយរងគ្រោះនៅកម្រិតសាលារៀន។ | ខែវិច្ឆិកា | អនុ គណៈកម្មការទី១ | លេខាធិការដ្ឋាន<br>អង្គការដៃគូ |
| លើកកម្ពស់ការយល់ដឹងពីហានិភ័យគ្រោះមហន្តរាយ ភាពងាយរងគ្រោះដល់សាលារៀន។ | ខែឧសភា | អនុ គណៈកម្មការទី១ | ការិយាល័យ អប់រំស្រុក<br>នាយកសាលា |

| សកម្មភាពត្រៀមបង្ការ និងកាត់បន្ថយហានិភ័យមុនគ្រោះមហន្តរាយ | ផែនការគ្រោងអនុវត្ត ( Plan to implement ) | អ្នកទទួលខុសត្រូវដឹកនាំ | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| ពង្រឹងសមត្ថភាពដល់មន្ត្រីបង្គោលថ្នាក់ជាតិស្តីពីការកាត់បន្ថយគ្រោះមហន្តរាយ | ខែធ្នូ | អនុគណៈកម្មការទី១ | លេខាធិការដ្ឋាន<br>អង្គការដៃគូ |
| ជំរុញឱ្យមានការបង្កើតគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយនៅតាមសាលារៀន និងពង្រឹងសមត្ថភាពស្តីពីការគ្រប់គ្រងកាត់បន្ថយគ្រោះមហន្តរាយ។ | ខែវិច្ឆិកា | អនុគណៈកម្មការទី១ | មន្ទីរ អយក.<br>ការិយាល័យអយក.<br>អង្គការដៃគូ |
| ត្រូវធានាថាថ្នាក់ក្រោមជាតិ ជាពិសេសសាលារៀនបានបង្កើតផែនការ ត្រៀមបម្រុងនិងឆ្លើយតបគ្រោះអាសន្ន និងអនុវត្តលំហាត់សមយុទ្ធបានទៀងទាត់។ | ខែមេសា និងឧសភា | អនុគណៈកម្មការទី១ | លេខាធិការដ្ឋាន<br>មន្ទីរ អយក.<br>ការិយាល័យអប់រំ |
| បង្កើតឱ្យមានឯកសារណែនាំដល់សាលារៀនក្នុងការបង្កើតផែនការត្រៀមបម្រុង និងឆ្លើយតបគ្រោះមហន្តរាយ | ខែមករាដល់ខែកុម្ភៈ | អនុគណៈកម្មការទី១ | លេខាធិការដ្ឋាន<br>អង្គការដៃគូ |
| ដឹកនាំសម្របសម្រួលប្រជុំជាមួយអ្នកពាក់ព័ន្ធនិងនាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ( EMIS)ដើម្បីបញ្ចូលឧបករណ៍ប្រមូលទិន្នន័យផលប៉ះពាល់គ្រោះមហន្តរាយនិងសាលារៀនសុវត្ថិភាព។ | ខែវិច្ឆិកា | អនុគណៈកម្មការទី១ | លេខាធិការដ្ឋាន<br>នាយកដ្ឋាន EMIS<br>អង្គការដៃគូ<br>នាយកដ្ឋានពាក់ព័ន្ធ |

| សកម្មភាពត្រៀមបង្ការ និងកាត់បន្ថយហានិភ័យមុនគ្រោះមហន្តរាយ | ផែនការគ្រោងអនុវត្ត ( Plan to implement ) | អ្នកទទួលខុសត្រូវដឹកនាំ | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| ធានាឱ្យបាននូវកិច្ចសហប្រតិបត្តិការល្អរវាងសាលារៀន ភាគីពាក់ព័ន្ធថ្នាក់ក្រោមជាតិ និងអង្គការដៃគូ។ | ខែមករា ឧសភា សីហា | អនុគណៈកម្មការទី១ | មន្ទីរ អ.យ.ក<br>ការិយាល័យ អ.យ.ក<br>អាជ្ញាធរដែនដី<br>សាលារៀន |
| សាលារៀនត្រូវធានាថាមានប្រព័ន្ធស្តីពី ការការពារកុមារ សុវត្ថិភាព និងសុខភាពរបស់កុមារ និងដំណើរការក្នុងពេលកើតមានគ្រោះមហន្តរាយ។ | ខែឧសភា | អនុគណៈកម្មការទី១ | មន្ទីរ អ.យ.ក<br>ការិយាល័យ អ.យ.ក<br>សាលារៀន |
| សាលារៀនត្រូវត្រៀមរៀបចំកន្លែងរៀនបណ្តោះអាសន្នសម្រាប់សិស្ស និងធានាឱ្យបានការអប់រំនៅតែបន្តក្នុងកំឡុងពេលមានគ្រោះមហន្តរាយកើតមាន។ | ខែឧសភា | អនុគណៈកម្មការទី១ | មន្ទីរ អ.យ.ក<br>ការិយាល័យ អ.យ.ក<br>សាលារៀន |
| ធ្វើផែនការសកម្មភាព និងថវិកាត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះមហន្តរាយ | ខែធ្នូ | អនុគណៈកម្មការទី២ | គណៈកម្មការទី១ ទី៣<br>លេខាធិការដ្ឋាន និងអង្គការដៃគូ |

| សកម្មភាពត្រៀមបង្ការ និងកាត់បន្ថយហានិភ័យមុនគ្រោះមហន្តរាយ | ផែនការគ្រោង អនុវត្ត ( Plan to implement ) | អ្នកទទួលខុសត្រូវ ដឹកនាំ | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| ត្រូវធ្វើបច្ចុប្បន្នកម្មផែនការនិងសកម្មភាពត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះអាសន្នជារៀងរាល់ឆ្នាំ | ខែធ្នូ | អនុគណៈកម្មការទី២ | គណៈកម្មការទី១ទី៣ លេខាធិការដ្ឋាន និងអង្គការដៃគូ |
| ផ្តល់វគ្គបណ្តុះបណ្តាលពីទស្សនទានគ្រប់គ្រងគ្រោះមហន្តរាយ និងយន្តការឆ្លើយតបគ្រោះមហន្តរាយ ដល់អ្នកពាក់ព័ន្ធ | ខែមីនា | អនុគណៈកម្មការទី២ | គណៈកម្មការទី១ ទី៣ លេខាធិការដ្ឋាន និងអង្គការដៃគូ |
| ផ្តល់វគ្គបណ្តុះបណ្តាលពីការប្រើប្រាស់ទម្រង់ប៉ាន់ប្រមាណ ក្នុងការចុះស្រង់ទិន្នន័យពីផលប៉ះពាល់លើវិស័យអប់រំដល់អ្នកពាក់ព័ន្ធ | ខែមីនា | អនុគណៈកម្មការទី២ | គណៈកម្មការទី១ ទី៣ លេខាធិការដ្ឋាន និងអង្គការដៃគូ |
| អនុវត្តលំហាត់សមយុទ្ធ | ខែឧសភា ដល់ខែមិថុនា | អនុគណៈកម្មការទី២ | គណៈកម្មការទី១ ទី៣ លេខាធិការដ្ឋាន និងអង្គការដៃគូ |
| កំណត់ផែនទីមុខសញ្ញាគ្រោះថ្នាក់ សម្រាប់វិស័យអប់រំ | ខែមករា ដល់ខែកុម្ភៈ | អនុគណៈកម្មការទី២ | គណៈកម្មការទី១ ទី៣ លេខាធិការដ្ឋាន និងអង្គការដៃគូ |
| កំណត់រួចជាស្រេចអំពីទីទួលសុវត្ថិភាពសម្រាប់ការសិក្សារៀនសូត្របណ្តោះអាសន្ន ក្នុងអំឡុងពេលមានគ្រោះមហន្តរាយ | ខែមករា ដល់ខែកុម្ភៈ | អនុគណៈកម្មការទី២ | គណៈកម្មការទី១ ទី៣ លេខាធិការដ្ឋាន និងអង្គការដៃគូ |

| សកម្មភាពត្រៀមបង្ការ និងកាត់បន្ថយហានិភ័យមុនគ្រោះមហន្តរាយ | ផែនការគ្រោងអនុវត្ត ( Plan to implement ) | អ្នកទទួលខុសត្រូវដឹកនាំ | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| បង្កើតទម្រង់របាយការណ៍ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់វិស័យអប់រំ | ខែមករាដល់ខែកុម្ភៈ | អនុគណៈកម្មការទី២ | គណៈកម្មាការទី១ ទី៣ លេខាធិការដ្ឋាន និងអង្គការដៃគូ |
| បង្កើតទម្រង់ប៉ាន់ប្រមាណ ក្នុងការចុះស្រង់ទិន្នន័យពីផលប៉ះពាល់លើវិស័យអប់រំ | ខែមករាដល់ខែកុម្ភៈ | អនុគណៈកម្មការទី២ | គណៈកម្មាការទី១ ទី៣ លេខាធិការដ្ឋាន និងអង្គការដៃគូ |
| ចងក្រង ក្រុមគាំទ្រកុមារផ្នែក សុខភាពផ្លូវចិត្ត សតិបញ្ញា និងការអភិវឌ្ឍ សម្រាប់វិស័យអប់រំ កំឡុងគ្រាអាសន្ន | ខែឧសភា | អនុគណៈកម្មការទី២ | គណៈកម្មាការទី១ ទី៣ លេខាធិការដ្ឋាន និងអង្គការដៃគូ |
| ផ្តល់វគ្គបណ្តុះបណ្តាល ផ្នែកសុខភាព ផ្លូវចិត្ត សតិបញ្ញា និងការអភិវឌ្ឍ សម្រាប់វិស័យអប់រំកំឡុងគ្រាអាសន្ន ដល់ក្រុមគាំទ្រកុមារ | ខែមិថុនា | អនុគណៈកម្មការទី២ | គណៈកម្មាការទី១ ទី៣ លេខាធិការដ្ឋាន និងអង្គការដៃគូ |
| បង្កើតទម្រង់ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារ | ខែមករាដល់ខែកុម្ភៈ | អនុគណៈកម្មការទី២ | គណៈកម្មាការទី១ ទី៣ លេខាធិការដ្ឋាន និងអង្គការដៃគូ |

| សកម្មភាពត្រៀមបង្ការ និងកាត់បន្ថយហានិភ័យមុនគ្រោះមហន្តរាយ | ផែនការគ្រោងអនុវត្ត ( Plan to implement ) | អ្នកទទួលខុសត្រូវដឹកនាំ | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| ពិនិត្យសម្ភារៈ តង់សម្រាប់ការសិក្សាបណ្ដោះអាសន្ន នាពេលមានគ្រោះមហន្តរាយ(ស្តង់ដា របស់ Child Centre Space/Child Friendly Space) | ខែមេសា | អនុគណៈកម្មការទី២ | គណៈកម្មាការទី១ ទី៣ លេខាធិការដ្ឋាន និងអង្គការដៃគូ |
| ចងក្រងនិងធ្វើបច្ចុប្បន្នភាពសទ្ធានុក្រមស្ថាបន័រដ្ឋ អង្គការ និងឯកជន ដែលផ្តល់សេវាសម្រាប់ត្រៀមឆ្លើយតប | ខែកុម្ភៈ | អនុគណៈកម្មការទី២ | គណៈកម្មាការទី១ ទី៣ លេខាធិការដ្ឋាន និងអង្គការដៃគូ |
| ធ្វើសន្និបាតបូកសរុបប្រចាំឆ្នាំសម្រាប់បទពិសោធ និងមេរៀនដែលបានជួបប្រទះពេលឆ្លើយតបគ្រោះមហន្តរាយ | ខែធ្នូ | អនុគណៈកម្មការទី២ លេខាធិការដ្ឋាន | គណៈកម្មាការទី១ ទី៣ និងអង្គការដៃគូ |
| សហការជាមួយនាយកដ្ឋានពាក់ព័ន្ធណែនាំដល់សាលារៀនឱ្យដាក់បញ្ចូល ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន និងលើកថវិកាក្នុងផែនការអភិវឌ្ឍសាលារៀន ។ | ខែកក្កដា-សីហា | -អនុគណៈកម្មការទី៣ | -នា.ពវ<br>-នា.ផក<br>-នា.ពអ និងEMIS |
| សហការជាមួយអនុគណៈកម្មការទី២ ដើម្បីកៀរគរថវិកាពីអង្គការដៃគូក្នុងការរៀបចំឆ្លើយតបគ្រោះមហន្តរាយ ។ | ខែកក្កដា-សីហា | -អនុគណៈកម្មការទី៣ | -អនុគណៈកម្មការទី២<br>-អង្គការដៃគូ |
| ប្រជុំអនុគណៈកម្មការទាំងបីក្រោយពីទទួលបានទិន្នន័យថវិកាក្នុងផែនការ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន ដើម្បីរៀបចំផែនការថវិកា ។ | ខែកញ្ញា | -អនុគណៈកម្មការទី៣ | -អនុគណៈកម្មការទី១ ទី២ |

| សកម្មភាពត្រៀមបង្ការ និងកាត់បន្ថយហានិភ័យមុនគ្រោះមហន្តរាយ | ផែនការគ្រោងអនុវត្ត ( Plan to implement ) | អ្នកទទួលខុសត្រូវដឹកនាំ | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| ការពារថវិកាជាមួយនាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំយុវជន និងកីឡា ដើម្បីធានាថវិកាត្រៀមបង្ការ កាត់បន្ថយហានិភ័យ និងឆ្លើយតបគ្រោះអាសន្នក្នុងវិស័យអប់រំ | | -អនុគណៈកម្មការទី៣ | -នា.ហវ |
| រៀបចំទម្រង់លិខិត និងនីតិវិធីនៃការស្នើសុំថវិកាសម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំពីក្រសួងអប់រំយុវជន និងកីឡា ។ | ខែកុម្ភៈ-មីនា | -អនុគណៈកម្មការទី៣<br>-លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ | -នា.ហវ<br>-អង្គការដៃគូពាក់ព័ន្ធ |
| សម្របសម្រួលឱ្យមានថវិកាសម្រាប់ លេខាធិការដ្ឋាន អនុគណៈកម្មការទី១ និងទី២ សម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំធានាឱ្យមានការឆ្លើយតបគ្រោះអាសន្នទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ | | -អនុគណៈកម្មការទី៣ | -អនុគណៈកម្មការទី១ និងទី២ |
| រៀបចំឯកសារសំណើសុំថវិកាទៅនាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំយុវជន និងកីឡាឬទៅអង្គការដៃគូ។ | | -អនុគណៈកម្មការទី៣ | -នា.ហវ<br>-អង្គការដៃគូ |
| ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ (ប្រចាំខែ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ) | រៀងរាល់ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ | -អនុគណៈកម្មការទី៣ | -អនុគណៈកម្មការទី១ ទី២ និងអង្គការដៃគូពាក់ព័ន្ធ |
| សេចក្តីណែនាំស្តីពីការត្រៀមបម្រុងឆ្លើយតប និងកាត់បន្ថយហានិភ័យដើម្បីធានាការបន្តការអប់រំ | នៅពេលមានហានិភ័យគ្រោះមហន្តរាយ | អនុគណៈកម្មការទី១ | លេខាធិការដ្ឋាន អនុគណៈកម្មការទី២ |

# ៩. ផែនការឆ្លើយតបបន្ទាន់ទៅនឹងគ្រោះទឹកជំនន់




*ប្រភព៖ World Food Programme/Humanitarian Response Forum*

*សម្គាល់៖ ផែនការឆ្លើយតបនេះ ត្រូវបានរៀបចំឡើងក្នុងលក្ខខណ្ឌចំណាត់ថ្នាក់ហានិភ័យគ្រោះមហន្តរាយក្នុងពេលធ្វើផែនការមានកម្រិតខ្ពស់ដែលទាមទារឱ្យធ្វើផែនការលម្អិតនេះ ។ ក្នុងករណី ហានិភ័យគ្រោះមហន្តរាយដទៃមានការកើនឡើងខ្ពស់ដែលនឹងទាមទារឱ្យមានការឆ្លើយតប លេខាធិការដ្ឋាន និងក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំ ត្រូវរៀបចំផែនការឆ្លើយតបគ្រោះមហន្តរាយសម្រាប់ហានិភ័យគ្រោះមហន្តរាយនោះ បន្ថែមទៀត( ឧ. គ្រោះរាំងស្ងួត)។ ផ្នែកនេះគឺបំពេញបន្ថែមលើកសកម្មភាពដែលមានចែងក្នុងផ្នែក ៨. ផែនការសកម្មភាពត្រៀមបង្ការអេប្បបរមានិងកាត់បន្ថយហានិភ័យមុនគ្រោះមហន្តរាយ។*

## គោលបំណង

- ធានាផ្តល់ការអប់រំប្រកបដោយសុវត្ថិភាព ទោះបីមានគ្រោះមហន្តរាយកើតឡើងក៏ដោយ
- កាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ រួមបញ្ចូលទាំងការបង្ការគ្រោះថ្នាក់ របួស ឬបាត់បង់ជីវិតនៅពេលមានគ្រោះមហន្តរាយ
- កាត់បន្ថយការខូចខាត និងបាត់បង់សម្ភារៈសិក្សា ឯកសារអប់រំ ឧបករណ៍បរិក្ខារ អនាម័យ និងគ្រឿងសង្ហារិមផ្សេងៗ នៅតាមសាលារៀន
- រក្សាបានប្រសិទ្ធភាពនៃការចុះឈ្មោះចូលរៀន ការចូលរៀនទៀងទាត់ គុណភាពសិក្សា និងលទ្ធផលសិក្សារបស់សិស្ស។

## ការឆ្លើយតបគ្រោះមហន្តរាយកម្រិតថ្នាក់ជាតិ

- ក្នុងគ្រាមានអាសន្ន ប្រធានគណៈកម្មការនៃយន្តការគ្រប់គ្រងគ្រោះមហន្តរាយវិស័យអប់រំ អាចធ្វើការសម្រេចចិត្តក្នុងការឆ្លើយតបគ្រោះអាសន្នកម្រិតថ្នាក់ជាតិ ទៅតាមស្ថានភាពចាំបាច់ ឬនៅពេលមាន៖
- ផលប៉ះពាល់ជាទូទៅ មានចំនួនច្រើនជាង២ខេត្ត
- សាលារៀនទទួលផលប៉ះពាល់ច្រើនជាង១០០០ សាលា
- ហួសសមត្ថភាពរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្តក្នុងការឆ្លើយតបទៅនឹងគ្រោះអាសន្នដែលកើតមាននៅក្នុងដែនរដ្ឋបាលរបស់ថ្នាក់ខេត្តនោះ
- ប្រជាពលរដ្ឋរងផលប៉ះពាល់ មានចំនួនច្រើនជាង៥០០០០០នាក់
- ប្រជាពលរដ្ឋជម្លៀស មានចំនួនច្រើនជាង១៥០០០០នាក់

## ការឆ្លើយតបបន្ទាន់ទៅនឹងគ្រោះមហន្តរាយទឹកជំនន់

| សកម្មភាពឆ្លើយតប | ស្ថាប័នទទួលខុសត្រូវដឹកនាំ | ផែនការថវិកា (រៀល) | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|
| ធ្វើសេចក្ដីសម្រេចចិត្តក្នុងការចេញសេចក្ដីណែនាំផ្អាកការសិក្សាបណ្ដោះអាសន្ន | ក្រសួងអយក. | | សាលារៀន ការិយាល័យ អយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត |
| ចេញសេចក្ដីណែនាំផ្អាកការសិក្សាបណ្ដោះអាសន្ន និងបំពេញបន្ថែមម៉ោងសិក្សា( ករណីធ្ងន់ធ្ងរ ) | ក្រសួងអយក. | | សាលារៀន ការិយាល័យ អយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត |
| កៀរគរធនធានរកជំនួយ ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ សម្រាប់វិស័យអប់រំ ( ធនធានមនុស្ស ថវិកា សម្ភារៈ និងអាហារ ) | ក្រសួងអយក. | | |
| ស្រង់ព័ត៌មានពីផលប៉ះពាល់ និងការខូចខាត ដើម្បីធ្វើរបាយការណ៍ជូនស្ថាប័នពាក់ព័ន្ធ | លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ (លេខាធិការដ្ឋាន គ.គ.ម. ) | | សាលារៀន ការិយាល័យ អយក ស្រុក ខណ្ឌ ក្រុង. មន្ទីរ អយក. ខេត្ត និងអង្គការដៃគូពាក់ព័ន្ធ |

| សកម្មភាពឆ្លើយតប | ស្ថាប័នទទួលខុសត្រូវដឹកនាំ | ផែនការថវិកា (រៀល) | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|
| រៀបចំរបាយការណ៍ពីផលប៉ះពាល់ជូនដល់ គ.ជ.គ.ម. | លេខាធិការដ្ឋាន គ.គ.ម. | | សាលារៀន ការិយាល័យ អយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត |
| ធ្វើបច្ចុប្បន្នភាពពីផលប៉ះពាល់គ្រោះមហន្តរាយសម្រាប់វិស័យអប់រំ និងរាយការណ៍ជូនអ្នកពាក់ព័ន្ធ | លេខាធិការដ្ឋាន គ.គ.ម. | | សាលារៀន ការិយាល័យ អយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត គ.ជ.គ.ម អង្គការដៃគូពាក់ព័ន្ធ |
| ផ្តល់សម្ភារៈផ្សព្វផ្សាយពីការការពារសុវត្ថិភាពសុខភាព( សត្វមានពិស អនាម័យ ការការពារ. . . ) | អនុគណៈកម្មការទី២ | | សាលារៀន ការិយាល័យអយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត ក្រសួងអភិ.ជនបទ ក្រសួងសុខាភិបាល អាជ្ញាធរ សហគមន៍ និងអង្គការដៃគូពាក់ព័ន្ធ |
| ប្រកាសដំណើរការសិក្សាក្រោយគ្រោះមហន្តរាយ | ក្រសួងអយក. | | សាលារៀន ការិយាល័យអយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត |
| ណែនាំ ធ្វើការផ្សព្វផ្សាយអប់រំ ពីការការពារសុវត្ថិភាព សុខភាព (សត្វមានពិស អនាម័យ ការការពារ. . . ) និងសេវាផ្តល់ប្រឹក្សាយោបល់ | អនុគណៈកម្មការទី២ | | សាលារៀន ការិយាល័យអយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត ក្រសួងអភិ.ជនបទ អាជ្ញាធរ សហគមន៍ និងអង្គការដៃគូពាក់ព័ន្ធ |

| សកម្មភាពឆ្លើយតប | ស្ថាប័នទទួលខុសត្រូវដឹកនាំ | ផែនការថវិកា (រៀល) | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|
| ផ្តល់ថវិកាជួសជុល និងសម្អាតបរិស្ថានសាលារៀន | អនុគណៈកម្មការទី៣ | | សាលារៀន ការិយាល័យ អយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត ក្រសួង អយក. ក្រសួងអភិ.ជនបទ អាជ្ញាធរ សហគមន៍ និងអង្គការដៃគូពាក់ព័ន្ធ |
| ផ្តល់សេចក្តីណែនាំ ដល់ថ្នាក់ក្រោមជាតិពីព័ត៌មានដល់មាតាបិតា សិស្ស និងអាជ្ញាធរពីស្ថានភាពគ្រោះមហន្តរាយសម្រាប់វិស័យអប់រំ | លេខាធិការដ្ឋាន គ.គ.ម. | | សាលារៀន ការិយាល័យអយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត ក្រសួង អយក. អាជ្ញាធរ សហគមន៍ និងអង្គការដៃគូពាក់ព័ន្ធ |
| ចេញសេចក្តីណែនាំ រៀបចំមធ្យោបាយ ដើម្បីជម្លៀសសិស្ស ( ទូក កាណូត អាវពោង ម៉ូតូកង់បី រ៉ឺម៉ក រទេះគោ.. ) | លេខាធិការដ្ឋាន គ.គ.ម. | | សាលារៀន ការិយាល័យអយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត ក្រសួង អយក. អាជ្ញាធរ សហគមន៍ និងអង្គការដៃគូពាក់ព័ន្ធ |

| សកម្មភាពឆ្លើយតប | ស្ថាប័នទទួលខុសត្រូវដឹកនាំ | ផែនការថវិកា(រៀល) | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|
| ចេញសេចក្តីណែនាំពីការជម្លៀសសិស្សទៅទីទួលសុវត្ថិភាព (ក្នុងពេលសិក្សា) | លេខាធិការដ្ឋាន គ.គ.ម. | | សាលារៀន ការិយាល័យ អយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត ក្រសួងអយក. អាជ្ញាធរ សហគមន៍ និងអង្គការដៃគូពាក់ព័ន្ធ |
| ផ្តល់ តង់ កន្ទេល ក្តារខៀន ធុងចម្រោះទឹក ដល់ថ្នាក់រៀនបណ្តោះអាសន្ន | លេខាធិការដ្ឋាន គ.គ.ម. | ១០០០សម្រាប់ *៧០០,០០០ រៀល | សាលារៀន ការិយាល័យ អយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត ក្រសួងអយក. អាជ្ញាធរ សហគមន៍ និងអង្គការដៃគូពាក់ព័ន្ធ |
| ចេញសេចក្តីណែនាំ បញ្ជូនសិស្សទៅបន្តការសិក្សានៅថ្នាក់រៀនបណ្តោះអាសន្ន | លេខាធិការដ្ឋាន គ.គ.ម. | | |
| ផ្តល់បង្គន់អនាម័យចល័ត និងទឹកស្អាត(ទឹកសុវត្ថិភាព) | លេខាធិការដ្ឋាន គ.គ.ម. និងក្រសួងពាក់ព័ន្ធ | ១០០បង្គន់ចល័ត*៨០០,០០០ រៀល | សាលារៀន ការិយាល័យ អយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត ក្រសួងអយក. ក្រសួងអភិវឌ្ឍជនបទ អាជ្ញាធរ សហគមន៍ និងអង្គការដៃគូពាក់ព័ន្ធ |

| សកម្មភាពឆ្លើយតប | ស្ថាប័នទទួលខុសត្រូវដឹកនាំ | ផែនការថវិកា (រៀល) | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|
| ផ្តល់ប្រអប់សង្គ្រោះបឋម (ប្រអប់សុវត្ថិភាព ) | លេខាធិការដ្ឋាន គ.គ.ម. | ១០០០ ប្រអប់ *២០០,០០០ | សាលារៀន ការិយាល័យ អយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត ក្រសួង អយក. |
| ផ្តល់សម្ភារៈរៀន និងបង្រៀន ដល់សិស្ស និងគ្រូ( សៀវភៅសិក្សាគោល ) | ក្រសួងអយក. | | សាលារៀន ការិយាល័យ អយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត ក្រសួង អយក. |
| ទទួលព័ត៌មានត្រឡប់ពីការឆ្លើយតប | លេខាធិការដ្ឋាន គ.គ.ម. | | សាលារៀន ការិយាល័យ អយក. ស្រុក ខណ្ឌ ក្រុង មន្ទីរ អយក. ខេត្ត ក្រសួង អយក. |

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១៧៥៣ អយក.ប្រក

## ប្រកាស
## ស្តីពី
## ការបង្កើតយន្តការគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួងអប់រំ យុវជន និងកីឡា
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញ អនុក្រឹត្យ លេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យ លេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៧១៥/០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១២១៥/១១៤១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោង ប្រកាស លេខ ៥៩៥ អយក.ប្រក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៃក្រសួងអប់រំ យុវជន និងកីឡា
- យោង សេចក្តីសម្រេច លេខ ២០ សសរ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយរបស់រាជរដ្ឋាភិបាល
- យោង លិខិត លេខ១៨៣ រ.ប គ.ជ.គ.ម. ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨ ស្តីពីការចាត់តាំងទីប្រឹក្សាបច្ចេកទេសយន្តការគ្រប់គ្រងគ្រោះមហន្តរាយក្រសួងអប់រំ យុវជន និងកីឡា

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ / ២១៧ ២៥៣ / ៤២៦ ៥៩១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

## សម្រេច

**ប្រការ១.**_ បង្កើតយន្តការគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួងអប់រំ យុវជន និងកីឡា ដោយមានគណៈកម្មការគ្រប់គ្រងដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១.ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហង់ជួន ណារ៉ុន** | រដ្ឋមន្ត្រី | ប្រធាន |
| ២.ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការ | អនុប្រធាន |

**ប្រការ២.**_ យន្តការគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួងអប់រំ យុវជន និងកីឡា មានឯកឧត្តម **ឃុន សុខា** ជាប្រធាននាយកដ្ឋាន ត្រៀមរៀបចំ និងបណ្តុះបណ្តាលនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ជាទីប្រឹក្សាជាតិនៃយន្តការគ្រប់គ្រងគ្រោះមហន្តរាយក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៣.**_ យន្តការគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួងអប់រំ យុវជន និងកីឡា មានរចនាសម្ព័ន្ធគ្រប់គ្រងដូចមានចែងក្នុងឧបសម្ព័ន្ធ១។

**ប្រការ៤.**_ យន្តការគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួងអប់រំ យុវជន និងកីឡា មានលេខាធិការដ្ឋានជាសេនាធិការ ដែលមានទីតាំងនៅនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១.លោកជំទាវ | **ទន់ សារ៉ុម** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២.ឯកឧត្តម | **ទេព តិយ៉ោរិទ្ធ** | ប្រធាននា.ហវ | អនុប្រធាន |
| ៣.ឯកឧត្តម | **ចាន់ សុតា** | ប្រធាននា.បស | អនុប្រធាន |
| ៤.ឯកឧត្តម | **ឃុន សុខា** | ប្រធាននា.គ.ជ.គ.ម. | ទីប្រឹក្សាបច្ចេកទេស |
| ៥-លោក | **ស៊ុន ប៊ុណ្ណា** | អនុប្រធាននា.អកស | សមាជិកអចិន្ត្រៃយ៍ |
| ៦.លោក | **ព្រីង មរកត** | ប្រធាននា.មចទ | មន្ត្រីបង្គោល |
| ៧.លោក | **លឹម សុវណ្ណា** | អនុប្រធាននា.សណ | មន្ត្រីបង្គោល |
| ៨.លោកស្រី | **ម៉ៅ តាន់ណាវី** | អនុការិ.នា.អកស | មន្ត្រីបង្គោល |
| ៩.លោកស្រី | **វ៉ាន់ សុភី** | អនុការិ.នា.អកស | ទទួលបន្ទុករដ្ឋបាល |
| ១០.លោក | **ថុល ប៊ុនថាត** | អនុការិ.នា.អកស | ទទួលបន្ទុកផែនការ |
| ១១.លោក | **ទិត្យ ប្រុស** | អនុការិ.នា.អកស | ទទួលបន្ទុកហិរញ្ញវត្ថុ |

**ប្រការ៥.**_ យន្តការគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួង អប់រំ យុវជន និងកីឡា មានអនុគណៈកម្មការបច្ចេកទេស ចំនួន៣៖

**អនុគណៈកម្មការទី១៖** ទទួលបន្ទុកការងារ កាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

**អនុគណៈកម្មការទី២៖** ទទួលបន្ទុកការងារ ត្រៀមរៀបចំឆ្លើយតបគ្រោះមហន្តរាយ។

**អនុគណៈកម្មការទី៣៖** ទទួលបន្ទុកការងាររៀបចំផែនការថវិកា និងកិច្ចការរដ្ឋបាលសម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយ។

**ប្រការ៦._** អនុគណៈកម្មការទី១ ទទួលបន្ទុកការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងបន្សាំនឹងការប្រែប្រួល អាកាសធាតុ មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-លោកជំទាវ | **ឃុន រចនា** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម | **លឹម សុធា** | អគ្គនាយក អគផ | អនុប្រធាន |
| ៣-ឯកឧត្តម | **ពុត សាមិត្ត** | អគ្គនាយក អគ.អរ | អនុប្រធាន |
| ៤-លោកបណ្ឌិត | **ហ៊ុន ចាន់រិទ្ធ** | អគ្គនាយករងអគ.រហ | អនុប្រធាន |
| ៥-ឯកឧត្តម | **ចាន់ សុតា** | ប្រធាននា.បស | សមាជិក |
| ៦-លោក | **សុក ថា** | ប្រធាននា.បវព | សមាជិក |
| ៧-លោក | **ថេត ប្រុស** | ប្រធាននា.សផក | សមាជិក |
| ៨-លោក | **ព្រីង មរកត** | ប្រធាននា.មចទ | សមាជិក |
| ៩-លោក | **ង៉ោ ប៉េងឡុង** | ប្រធាននា.បវ | សមាជិក |
| ១០-លោក | **គង់ ភូមិភា** | ប្រធាននា.ឧស | សមាជិក |
| ១១-លោក | **ខង ភិរុណ** | ប្រធាននា.សណ | សមាជិក |
| ១២-លោក | **ឆឹង យ៉ុង** | អនុប្រធាននា.បវ | សមាជិក |
| ១៣-លោកស្រី | **ម៉ៅ តាន់ណាវី** | អនុប្រធានការិ.នា.អកស | សមាជិក |
| ១៤-លោក | **អេង វ៉ាត់** | អនុប្រធានការិ.នា.អកស | សមាជិក |
| ១៥-លោក | **សូ ស៊ីផុន** | អនុប្រធានការិ.នា.អពស | សមាជិក |
| ១៦-លោកស្រី | **សេង ពិសិដ្ឋនារី** | មន្ត្រីនា.អកស | សមាជិក |
| ១៧-លោក | **ដាំ បេង** | មន្ត្រីនា.អកស | សមាជិក |
| ១៩-លោក | **សុខ បញ្ញាវឌ្ឍន៍** | មន្ត្រីនា.អកស | សមាជិក |

**ប្រការ៧._** អនុគណៈកម្មការទី២ ទទួលបន្ទុកការងារ ទទួលបន្ទុកការងារ ត្រៀមរៀបចំឆ្លើយតបគ្រោះមហន្តរាយ មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-លោកជំទាវ | **គីម សេដ្ឋានី** | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម | **ហ៊ាង ស៊ីណោ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម | **ហាន ឌីទីន** | ប្រធាននា.របេ | អនុប្រធាន |
| ៤-លោក | **លី សទ្ធិ** | អគ្គនាយករង អគ.រហ | អនុប្រធាន |
| ៥-លោកបណ្ឌិត | **ម៉ុក សារ៉ុម** | អគ្គនាយករង អគ.អរ | សមាជិក |
| ៦-ឯកឧត្តម | **ស៊ីន សេងហុក** | ប្រធាននា.នក | សមាជិក |
| ៧-ឯកឧត្តម | **ប្រាក់ កុសល** | ប្រធាននា.អកត | សមាជិក |
| ៨-លោក | **រ៉េន សុភាព** | ប្រធានអង្គភាពលទ្ធកម្ម | សមាជិក |
| ៩-លោក | **អាច់ ឃាង** | ប្រធាននា.សទរ | សមាជិក |
| ១០-លោកស្រី | **ឆាយគីម សុខ្វាវី** | ប្រធាននា.សស | សមាជិក |

| | | | |
|---|---|---|---|
| ១១.លោក | **ស សុភាព** | ប្រធាននា.ពវ | សមាជិក |
| ១២.លោក | **លឹម សុវណ្ណា** | អនុប្រធាននា.សណ | សមាជិក |
| ១៣.លោក | **ឃឹម សារិន** | អនុប្រធាននា.អកស | សមាជិក |
| ១៤.លោក | **ឈឿន រចនា** | ប្រធានការិ.នា.ពអ | សមាជិក |
| ១៥.លោក | **ឡេង សារី** | អនុប្រធានការិ.នា.អកស | សមាជិក |
| ១៦.លោក | **ស៊ឹមចាន់ សុវណ្ណារិទ្ធ** | មន្ត្រីនា.បស | សមាជិក |
| ១៧.លោកស្រី | **ទេព ម៉ុណ្ណារី** | មន្ត្រីនា.អកស | សមាជិក |

**ប្រការ៨._** អនុគណៈកម្មការទី៣ ទទួលបន្ទុកការងាររៀបចំផែនការថវិកា និងកិច្ចការរដ្ឋបាលសម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយ មានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១.ឯកឧត្តមបណ្ឌិត | **អ៊ឹម កុច** | រដ្ឋលេខាធិការ | ប្រធាន |
| ២.ឯកឧត្តម | **ថោង ប៊ូរ៉ាន់** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣.ឯកឧត្តម | **ខួន មាស** | អគ្គនាយក អគ.រហ | អនុប្រធាន |
| ៤.ឯកឧត្តម | **ទេព តិយ៉ោរិទ្ធ** | ប្រធាននា.ហវ | អនុប្រធាន |
| ៥.ឯកឧត្តម | **ទៀ សុផន** | ប្រធាននា.បល | សមាជិក |
| ៦.លោក | **ញ៉ាំ ស៊ីនិត** | ប្រធាននា.ផក | សមាជិក |
| ៧.ឯកឧត្តមបណ្ឌិត | **ឌី ខាំបូលី** | ប្រធាននា.គប | សមាជិក |
| ៨.លោក | **ហាន រដ្ឋា** | អនុប្រធានការិ.នា.សទរ | សមាជិក |
| ៩.លោក | **ម៉ៅ សុធី** | ប្រធានលេខាធិការដ្ឋានអគ.រហ | សមាជិក |
| ១០.លោក | **ស៊ិន ម៉ុណ្ណា** | អនុប្រធាននា.អកស | សមាជិក |
| ១១.លោកស្រី | **វ៉ាន់ សុភី** | អនុការិ.នា.អកស | សមាជិក |
| ១២.លោក | **យ៉េង គំស៊ាន** | អនុការិ.នា.អកស | សមាជិក |
| ១៣.លោក | **ទិត្យ ប្រុស** | អនុការិ.នា.អកស | សមាជិក |
| ១៤.លោក | **ថុល ម៉ិនថាត** | អនុការិ.នា.អកស | សមាជិក |
| ១៥.លោក | **គី ជន់** | អនុការិ.នា.អកស | សមាជិក |
| ១៦.លោក | **អេង សាន់** | មន្ត្រីនា.សណ | សមាជិក |
| ១៧.កញ្ញា | **ឈុន សុរិយា** | មន្ត្រីនា.អកស | សមាជិក |

**ប្រការ៩._** យន្តការគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ច និងការទទួលខុសត្រូវសំខាន់ៗដូចមានចែងក្នុងឧបសម្ព័ន្ធ២។

**ប្រការ១០._** យន្តការគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួងអប់រំ យុវជន និងកីឡាត្រូវបង្កើតគណៈកម្មការគ្រប់គ្រង និងប្រើប្រាស់ ថវិកាសម្រាប់ដំណើរការនិងប្រព្រឹត្តទៅក្រោមការដឹកនាំគ្រប់គ្រងនិង សម្របសម្រួលពីប្រធានអនុគណៈកម្មការទី៣ ទទួលបន្ទុកកិច្ចការផែនការថវិកា និងកិច្ចការរដ្ឋបាលសម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ១១**._ យន្តការគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួងអប់រំ យុវជន និងកីឡាត្រូវមានកញ្ចប់ថវិកាសម្រាប់ដំណើរការ និងការប្រព្រឹត្តទៅ ក្រោមការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលដោយប្រធាន អនុគណៈកម្មការទី៣។

**ប្រការ១២**._ យន្តការគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួងអប់រំ យុវជន និងកីឡា មានដំណើរការនិងប្រព្រឹត្តទៅក្រោមការដឹកនាំសម្របសម្រួលដោយ ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ជាប្រធាន និងប្រធានលេខាធិការដ្ឋានដោយមានការរៀបចំផែនការប្រចាំឆ្នាំ និងត្រីមាស សម្រាប់គ្រប់គ្រង ព្រមទាំងអនុវត្តមុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ។

**ប្រការ១៣**._ នាយកខុទ្ទកាល័យ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងសមាជិក សមាជិកាក្រោមឱវាទក្រសួង អប់រំ យុវជន និងកីឡាត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ [illegible]
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៩

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន គ.ជ.គ.ម.
- សាលារាជធានី-ខេត្ត
- អគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរ អយក រាជធានី ខេត្ត
- គ្រប់អង្គភាពក្រោមឱវាទទីស្តីការក្រសួង អយក "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នា. អកស

# រចនាសម្ព័ន្ធ
# យន្តការគ្រប់គ្រងគ្រោះមហន្តរាយ
# នៃក្រសួងអប់រំ យុវជន និងកីឡា



ឧបសម្ព័ន្ធទី ២

# តួនាទី និងភារកិច្ច ការទទួលខុសត្រូវ យន្តការគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួងអប់រំ យុវជន និងកីឡា

## ១- តួនាទី និងភារកិច្ច ការទទួលខុសត្រូវ នៃគណៈគ្រប់គ្រង

ប្រធាន និងអនុប្រធានយន្តការគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួងអប់រំ យុវជន និងកីឡាមានភារកិច្ចក្នុងការទទួលខុសត្រូវរួម គ្រប់អនុគណៈកម្មការទាំងអស់ដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួល និងចាត់ចែងការងារពាក់ព័ន្ធនឹងការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំ ទាំងមុនពេល ក្នុងពេល និង ក្រោយពេលមានគ្រោះមហន្តរាយដោយអនុលោម តាមច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងលិខិតបទដ្ឋានផ្សេងៗទៀតដែលពាក់ព័ន្ធ។
- ផ្តល់ការគាំទ្រ ដល់លេខាធិការដ្ឋាន និងអនុគណៈកម្មការទាំងបី ក្នុងការបំពេញការងារ របស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់។
- សម្របសម្រួលការងារពាក់ព័ន្ធនឹងការងារគ្រប់គ្រងគ្រោះមហន្តរាយ ជាមួយបណ្តាក្រសួងពាក់ព័ន្ធ និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។
- ដឹកនាំនិងសម្របសម្រួលធ្វើផែនការសម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំ។
- ពិនិត្យនិងអនុម័តរាល់សេចក្តីសម្រេច ដែលទាក់ទងទៅនឹងបទដ្ឋានគតិយុត្តិនានា ធានាបាននូវដំណើរការការអនុវត្ត និងភាពជោគជ័យសម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំ។
- ករណីប្រធានអវត្តមាន ប្រធានត្រូវធ្វើប្រតិភូកម្មការងារជូនដល់អនុប្រធាន។
- កោះប្រជុំប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ ជាមួយលេខាធិការដ្ឋាន និងអនុគណៈកម្មការទាំងបី ដើម្បីបូកសរុប ផ្ទៀងផ្ទាត់ និងលើកទិសដៅបន្ត។
- ករណីគ្រាមានអាសន្ន និងគ្រោះមហន្តរាយត្រូវកោះប្រជុំជាបន្ទាន់ជាមួយលេខាធិការដ្ឋាន និងអនុគណៈកម្មការទាំងបី ដើម្បីត្រៀមឆ្លើយតបគ្រោះអសន្ន និងស្តារឡើងវិញទាន់ពេលវេលា។
- លើកសំណើជូនរាជរដ្ឋាភិបាលអំពីតម្រូវការនិងការត្រៀមបម្រុង ថវិកា ធនធាន និងសម្ភារៈ និងអំពាវនាវរកជំនួយដើម្បីគាំទ្រការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំ។

## ២- តួនាទី និងភារកិច្ច ការទទួលខុសត្រូវ របស់លេខាធិការដ្ឋាន

### ២-១ លេខាធិការដ្ឋាន

លេខាធិការដ្ឋានមានភារកិច្ចរួម ជាសេនាធិការឱ្យយន្តការគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងអប់រំ យុវជន និងកីឡា។ លេខាធិការដ្ឋានដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលរាល់ការងារទំនាក់ទំនងទៅនឹងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីធានាបានការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំប្រកបដោយប្រសិទ្ធភាព។ លេខាធិការដ្ឋានមានភារកិច្ចដូចខាងក្រោម៖

- ដើរតួជាមន្ត្រីបង្គោលក្នុងការសម្របសម្រួល និងចែករំលែកព័ត៌មានការងារគ្រប់គ្រងគ្រោះមហន្តរាយជាមួយ អនុគណៈកម្មការទាំងបី គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងដៃគូពាក់ព័ន្ធ ក្រោមការគាំទ្ររបស់ គណៈគ្រប់គ្រងទាំងការងារមុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ។
- កសាង និងអនុវត្តផែនការគ្រប់គ្រងគ្រោះមហន្តរាយរបស់យន្តការទាំងមូល រួមទាំងលេខាធិការដ្ឋានផ្ទាល់ដោយ សម្របសម្រួលជាមួយគ្រប់ភាគីពាក់ព័ន្ធ ដែលមាននាយកដ្ឋានពាក់ព័ន្ធ និងអង្គការដៃគូ។
- ផ្សព្វផ្សាយផែនការដល់សមាជិកសមាជិកា និងអ្នកពាក់ព័ន្ធទាំងនៅ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ចូលរួមអនុវត្តផែនការ តាមដានត្រួតពិនិត្យ និងវាយតម្លៃការងារគ្រប់គ្រងគ្រោះមហន្តរាយ សម្រាប់វិស័យរបស់ ខ្លួនជាប្រចាំជាមួយ ថ្នាក់ក្រោមជាតិ សង្គមស៊ីវិល អង្គការដៃគូពាក់ព័ន្ធនានា។
- សហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងធ្វើការទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ដើម្បីផ្តល់ ព័ត៌មានគ្នាទៅវិញទៅមក និងឆ្លើយតបទាន់ពេលវេលា។
- ប្រជុំលើកបញ្ហា និងសំណើតម្រូវការថវិកា សម្រាប់គាំទ្រដល់កម្មវិធីនានាទាក់ទងលេខាធិការដ្ឋាន ក្នុងការ ដោះស្រាយ បញ្ហាដែលកើតឡើងទាំងមុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ ឬតម្រូវការចាំបាច់ ជាបន្ទាន់ផ្សេងៗដូចជា ការត្រៀមបង្ការ ឆ្លើយតប សង្គ្រោះបន្ទាន់ ជួសជុល ឬកសាងឡើងវិញ ការខូចខាត សម្ភារៈសិក្សា អគារសិក្សាដែលរងផលប៉ះពាល់ ដោយគ្រោះមហន្តរាយ។
- ពង្រឹងទំនាក់ទំនង កិច្ចសហការ និងសុំអន្តរាគមន៍ពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយក្នុងករណី ចាំបាច់ ដើម្បីចូលរួមទប់ស្កាត់ កាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយដែលកើតឡើង។
- ប្រមូលព័ត៌មាន និងបូកសរុបរបាយការណ៍ពីថ្នាក់ក្រោមជាតិ រាល់ករណីជួបបញ្ហាគ្រោះមហន្តរាយ និងបន្តចែក រំលែកដល់ គណៈគ្រប់គ្រងយន្តការ អនុគណៈកម្មការទាំងបី គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោមហន្តរាយ និងដៃគូពាក់ព័ន្ធ។

**២-២ ប្រធាន និងអនុប្រធាន លេខាធិការដ្ឋាន**

- មានភារកិច្ចដឹកនាំ ដើម្បីសម្រេចនូវភារកិច្ចដែលចែងក្នុងចំណុច ២-១
- ប្រធានត្រូវចាត់តាំង ឬធ្វើប្រតិភូកម្មការងារដល់មន្ត្រីបង្គោលណាមួយនៅពេលប្រធានអវត្តមាន។
- កោះប្រជុំប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ ឬករណីបន្ទាន់ជាមួយសមាជិកលេខាធិការដ្ឋានទាំងអស់ តំណាង អនុគណៈកម្មការទាំងបី និងអ្នកពាក់ព័ន្ធ ដើម្បីបូកសរុប ផ្ទៀងផ្ទាត់ និងលើកទិសដៅបន្ត។
- កោះប្រជុំបន្ទាន់ ករណីមានគ្រោះអសន្ន និងគ្រោះមហន្តរាយជាមួយសមាជិកលេខាធិការដ្ឋានទាំងអស់ តំណាងអនុគណៈកម្មការទាំងបី និងអ្នកពាក់ព័ន្ធដើម្បីត្រៀមឆ្លើយតបគ្រោះអាសន្ន និងស្តារឡើងវិញទាន់ ពេលវេលា។

**២-៣ មន្ត្រីបង្គោល និងសមាជិក លេខាធិការដ្ឋាន**

- ជាជំនួយការនៃការងារដល់ប្រធាន និងគណៈគ្រប់គ្រង ហើយបំពេញភារកិច្ចតាមការចាត់តាំង របស់ប្រធាន ឬគណៈគ្រប់គ្រង
- រៀបចំទុកដាក់ឯកសារផ្សេងៗដែលពាក់ព័ន្ធ

- រៀបចំកិច្ចប្រជុំឬសិក្ខាសាលានានាពាក់ព័ន្ធការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនិងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- សម្របសម្រួលរាល់ការងារទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ស្ថាប័នឬអង្គការដៃគូពាក់ព័ន្ធ
- ធ្វើកំណត់ហេតុឬរបាយការណ៍ប្រចាំត្រីមាសឬឆមាសនីមួយៗដើម្បីជូនប្រធានលេខាធិការដ្ឋាននិងគណៈគ្រប់គ្រង ក្រសួង អប់រំ យុវជន និងកីឡា។

**៣- ភារកិច្ច និងការទទួលខុសត្រូវ របស់អនុគណៈកម្មការនីមួយៗ**

**៣-១ អនុគណៈកម្មការទី១**

អនុគណៈកម្មការទី ១ មានភារកិច្ចរួមក្នុងការលើកកម្ពស់ការអនុវត្តការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យអប់រំ ដែលមានភារកិច្ចជាក់លាក់ដូចខាងក្រោម៖

- បញ្ជ្រាបការងារ កាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួល អាកាសធាតុក្នុងកម្មវិធីសិក្សាគ្រប់កម្រិតថ្នាក់
- ពង្រឹងសមត្ថភាពដល់មន្ត្រីពាក់ព័ន្ធថ្នាក់ជាតិលើការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅគ្រប់កម្រិត
- លើកកម្ពស់ការយល់ដឹងពីហានិភ័យ និងភាពងាយរងគ្រោះទៅនឹងគ្រោះមហន្តរាយនៅតាមសាលារៀន
- ផ្តល់ព័ត៌មានជាមុនពីមុខសញ្ញាគ្រោះថ្នាក់នៃគ្រោះមហន្តរាយណាមួយដែលអាចកើតឡើងនៅតាមសាលារៀន
- បង្កើតគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយនៅតាមសាលារៀន
- រៀបចំយុទ្ធនាការផ្សព្វផ្សាយ និងកម្មវិធីប្រឡងប្រណាំងនៅតាមសាលារៀនគ្រប់ភូមិសិក្សា
- ប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាព នៅតាមតាមសាលារៀន
- រៀបចំផែនការមេក្នុងការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- រៀបចំផែនការត្រៀមឆ្លើយតប និងឆ្លើយតបគ្រោះមហន្តរាយនៅតាមសាលារៀន
- សាងសង់សាលារៀនដែលមានភាពធន់នឹងគ្រោះមហន្តរាយ រួមទាំងសម្ភារៈបរិក្ខារនៅតាមសាលារៀនឱ្យមានភាពធន់ នឹងគ្រោះមហន្តរាយ
- បង្កើនកិច្ចសហការនៅកម្រិតអាស៊ាន និងអន្តរជាតិក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ
- ចូលរួមសហការ និងគាំទ្រដល់ការងារលេខាធិការដ្ឋាន អនុគណៈកម្មការទី២ និង ទី៣ នៅពេលមានតម្រូវការចាំបាច់។

**៣-២ ប្រធាន និង អនុប្រធានគណៈកម្មការទី១**

- មានភារកិច្ចដឹកនាំសម្របសម្រួលដើម្បីសម្រេចនូវភារកិច្ចដែលចែងក្នុងចំណុច ៣-១
- ប្រធានត្រូវធ្វើប្រតិភូកម្ម ការងារដូចក្នុងចំណុច ៣-១ ជូនដល់អនុប្រធានក្នុងករណីប្រធានអវត្តមាន។

**៣-៣ សមាជិកអនុគណៈកម្មការទី១**

សមាជិក សមាជិកាទាំងអស់ មានភារកិច្ចចូលរួមអនុវត្តការងារដែលមានចែងក្នុង ៣-១ ទៅតាមជំនាញ និងការចាត់ចែង របស់ប្រធាន ឬអនុប្រធាន។

**៤- ភារកិច្ច និងការទទួលខុសត្រូវ របស់អនុគណៈកម្មការទី ២**

**៤-១ អនុគណៈកម្មការទី២**

អនុគណៈកម្មការទី ២ មានភារកិច្ចរួមក្នុងការលើកកម្ពស់ការអនុវត្តការងារត្រៀមរៀបចំឆ្លើយតប និងការងារឆ្លើយតបនឹងគ្រោះមហន្តរាយក្នុងវិស័យអប់រំ ដែលមានភារកិច្ចជាក់លាក់ដូចខាងក្រោម៖

- រៀបចំបង្កើត និងគ្រប់គ្រងក្រុមការងារឆ្លើយតបគ្រោះមហន្តរាយ ក្រសួងអប់រំ យុវជន និងកីឡា ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពង្រឹងសមត្ថភាពក្រុមការងារឆ្លើយតបក្រសួងអប់រំ យុវជន និងកីឡា
- ត្រៀមនិងស្តុកទុកសម្ភារៈនិងទំនិញផ្សេងៗសម្រាប់ឆ្លើយតប
- ប៉ាន់ប្រមាណ និងប្រមូលព័ត៌មានពាក់ព័ន្ធផ្សេងៗនៅគ្រាអាសន្ន
- ការពារ និងរក្សាទឹកស្អាត អនាម័យតាមសាលារៀន
- ជម្លៀស និងអប់រំនៅគ្រាអាសន្ន
- សម្របសម្រួល និងទាក់ទងការងារផ្សេងៗនាគ្រាអាសន្ន
- គ្រប់គ្រងសាលារៀនដែលជាទីតាំងជម្លៀស និងគ្រប់គ្រងទីកន្លែងដែលជាទីសម្រាប់ការអប់រំបណ្តោះអាសន្ន
- រៀបចំផែនការត្រៀមឆ្លើយតប និងឆ្លើយតបរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំលំហាត់សមយុទ្ធឆ្លើយតបគ្រោះមហន្តរាយ សម្រាប់វិស័យអប់រំ
- ចូលរួមសហការ និងគាំទ្រដល់ការងារលេខាធិការដ្ឋាន អនុគណៈកម្មការទី១ និងទី៣ នៅពេលមានតម្រូវការចាំបាច់។

**៤-២ ប្រធាន និងអនុប្រធាន អនុគណៈកម្មការទី ២**

- មានភារកិច្ចដឹកនាំ សម្របសម្រួលដើម្បីសម្រេចនូវភារកិច្ចដែលចែងក្នុងចំណុច ៤-១
- ប្រធានត្រូវធ្វើប្រតិភូកម្ម ការងារដូចក្នុងចំណុច ៤-១ ជូនដល់អនុប្រធានក្នុងករណីប្រធានអវត្តមាន។

**៤-៣ សមាជិក អនុគណៈកម្មការទី ២**

សមាជិក សមាជិកាទាំងអស់ មានភារកិច្ចចូលរួមអនុវត្តការងារដែលមានចែងក្នុងចំនុច ៤-១ ទៅតាមជំនាញ និងការចាត់ចែងរបស់ប្រធាន ឬអនុប្រធាន។

**៥- ភារកិច្ច និងការទទួលខុសត្រូវ របស់អនុគណៈកម្មការទី ៣**

**៥-១ អនុគណៈកម្មការទី ៣**

អនុគណៈកម្មការទី៣មានភារកិច្ចរួមក្នុងការសម្របសម្រួលជាមួយលេខាធិការដ្ឋាន អនុគណៈកម្មការទី១ និងទី២ ដើម្បី អនុវត្តភារកិច្ចជាក់លាក់ដូចខាងក្រោម៖

- សហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាន អនុគណៈកម្មការទី១ និង ទី២ ដើម្បីបញ្ជ្រាបការគ្រប់គ្រងគ្រោះមហន្តរាយ ដែលបានពីលេខាធិការដ្ឋាន អនុគណៈកម្មការទី១ និងទី២ ក្នុងផែនការមេ របស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំគម្រោងថវិកា សម្រាប់អនុវត្តការងារគ្រប់គ្រងគ្រោះមហន្តរាយទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងារគ្រប់គ្រងគ្រោះមហន្តរាយ

- ប្រមូល គ្រប់គ្រង និងចែកចាយ រាល់របាយការណ៍នៃការងារគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ចូលរួមសហការ និងគាំទ្រដល់ការងារលេខាធិការដ្ឋាន អនុគណៈកម្មការទី១ និងទី២ នៅពេលមានតម្រូវការចាំបាច់។

**៥-២ ប្រធាន និងអនុប្រធាន អនុគណៈកម្មការទី៣**

- មានភារកិច្ចដឹកនាំ សម្របសម្រួលដើម្បីសម្រេចនូវភារកិច្ចដែលចែងក្នុងចំណុច ៥-១
- ប្រធានត្រូវធ្វើប្រតិភូកម្ម ការងារដូចក្នុងចំណុច៥-១ ជូនដល់អនុប្រធានក្នុងករណីប្រធានអវត្តមាន។

**៥-៣ សមាជិកអនុគណៈកម្មការទី៣**

សមាជិកទាំងអស់មានភារកិច្ចចូលរួមអនុវត្តការងារដែលមានចែងក្នុងចំណុច ៥-១ ទៅតាមជំនាញ និងការចាត់ចែងរបស់ប្រធាន ឬអនុប្រធាន។

ទទួលបានសេចក្តីណែនាំនេះ សូមឯកឧត្តម លោកជំទាវ លោក លោកស្រីជាប្រធាន អនុប្រធាន សមាជិក សមាជិកាទាំងអស់របស់លេខាធិការដ្ឋាន និងយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៃក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានពាក់ព័ន្ធ និងគ្រឹះស្ថានអប់រំសាធារណៈទាំងអស់ក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ចាត់តាំងអនុវត្តទៅតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ២កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែ សីហា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល**

-អគ្គលេខាធិការ គជគម "ដើម្បីជ្រាបជាព័ត៌មាន"
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
-សាលារាជធានី-ខេត្ត "ដើម្បីជ្រាបជាព័ត៌មាន"
-អគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរ អយក រាជធានី ខេត្ត ពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជ្រាបជាព័ត៌មាន និងមុខការ"
-លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយក្រសួង អយក "ដើម្បីមុខការ"
-សាមីជន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ នា. អកស

# ឧបសម្ព័ន្ធទី ៣៖ បញ្ជីទំនាក់ទំនងរបស់ក្រុមការងារ

| ឈ្មោះសមាជិកក្រុម | ឋានៈ និងតួនាទី | លេខទូរស័ព្ទ និងអ៊ីមែល |
|---|---|---|
| ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា | hangnaron@yahoo.com 012843889 |
| ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន | រដ្ឋលេខាធិការ | 012513366 |
| ឯកឧត្តម យុន សុខា | តំណាង គ.ជ.គ.ម | 012882198 |
| លោកជំទាវ ទន់ សាអ៊ីម | អនុរដ្ឋលេខាធិការ | 012869458/011918873 |
| លោកជំទាវ យុន រចនា | អនុរដ្ឋលេខាធិការ | 012782561 |
| លោកជំទាវ គឹម សេដ្ឋានី | រដ្ឋលេខាធិការ | 012335999 |
| ឯកឧត្តម ហ៊ាង ស៊ីណេ | អនុរដ្ឋលេខាធិការ | 077959797 |
| ឯកឧតម្តបណ្ឌិត អ៊ឹម កុច | រដ្ឋលេខាធិការ | 0125691554 |
| ឯកឧត្តម ថោង បូរ៉ាន់ | អនុរដ្ឋលេខាធិការ | 012812115 |
| ឯកឧត្តម លឹម សុជា | អគ្គនាយក អគ.អគផ | 012535617 |
| ឯកឧត្តម ពុត សាមិត្ត | អគ្គនាយក អគ.អរ | 012914297 |
| ឯកឧត្តម ងួន មាស | អគ្គនាយក អគ.រហ | 016507070 |
| ឯកឧត្តម ទេព ភិយ្យោរិទ្ធ | ប្រធាន នា.ហវ | 012866757 |
| ឯកឧត្តម ហាន ឌីរីន | ប្រធាន នា. រប | 012502602 |
| ឯកឧត្តម ស៊ិន សេងហុក | ប្រធាន នា.នក | 012586554 |
| ឯកឧត្តម ចាន់ សុភា | ប្រធានយកដ្ឋានបឋម | 012211336 |
| ឯកឧត្តម ប្រាក់ កុសល | ប្រធាន នា. អកត | 012824256 |
| ឯកឧត្តម នៀ សុផន | ប្រធាន នា. បល | 012751109 |
| ឯកឧត្តម ឌី ខាំបូលី | អគ្គនាយករង អគ.ផគ | 017883967 |
| លោក លី សទ្ធិ | អគ្គនាយករង អគ.រហ | 012911524 |
| លោកបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយករង អគ.អរ | 017373855 |
| លោកបណ្ឌិត ហ៊ុន ចាន់រិទ្ធ | អគ្គនាយករង អគ. រហ | 012831634 |
| លោក ស៊ុន ប៊ុណ្ណា | អនុប្រធាននា.អកស. | 012868656 |
| លោក ព្រឹង មរកត | ប្រធាន នា.មចទ | 012970987 |
| លោក ង៉ោ ប៉េងឡុង | ប្រធាននា. បវ | 077982983 |
| លោក គង់ ភូមិកា | ប្រធានា. ឧស | 012330801 |
| លោក លោក វង ភិរុណ | ប្រធាន នា. សណ | 012900779 |

| ឈ្មោះសមាជិកក្រុម | ឋានៈ និងតួនាទី | លេខទូរស័ព្ទ និងអ៊ីមែល |
|---|---|---|
| លោក ស សុភាព | ប្រធាន នា. ពវ | 092511512 |
| លោក អាប់ ឃាង | ប្រធាន នា. សទវ | 012843585 |
| លោកស្រី ឆាយ គីមសុទ្ធាវី | ប្រធាន នា. សស | 011973757 |
| លោក ស៊ុន សេង | ប្រធាន នា. នក | 012586554 |
| លោក ញ៉ាំ ស៊ីនិត | អគ្គនាយករង អគ.ផគ | 012820496 |
| លោក លឹម សុវណ្ណា | អនុប្រធាន នា. សណ | 078478847 |
| លោក ឃឹម សារិន | អនុប្រធាន នា. អកស | 011860511 |
| លោក ហាន វឌ្ឍា | ប្រធាន ការិ.នា. សទវ | 012353949 |
| លោក រ៉េន សុភាព | ប្រធានអង្គភាពលទ្ធកម្ម | 012990406 |
| លោក ថេត ប្រុស | ប្រធាននា.សផក | 012557344 |
| លោក សុក ថា | ប្រធាន នា. បវព | 011/066 901801 |
| លោក ឈឿន រចនា | ប្រធានការិ. នា.ពអ | 077999089 |
| លោក ថុល ប៊ុនថាត | អនុ. ការិ. នា. អកស | 017596905 |
| លោកស្រី ម៉ៅ តាន់ណារី | អនុប្រធានការិ.នា. អកស | 012559685 |
| លោក អេង វ៉ាត់ | អនុប្រធានការិ. នា. អកស | 011889435 |
| លោក ទិត្យ ប្រុស | អនុ. ការិ. នា.អកស | 098336777 |
| លោក សូ ស៊ីផុន | អនុប្រធានការិ.នា. អពស | 012754461 |
| លោក ភី ជន់ | អនុការិ នា. អកស | 012913872 |
| លោក ធឹង យ៉ុង | អនុប្រធាន នា. បវ | 012757380 |
| លោក ម៉ៅ សុជី | ប្រធានលេខាធិការដ្ឋានអគ.រហ | 016915123 |
| លោក អេង សាន់ | មន្ត្រី នា.សណ | 070781372 |
| លោក ឡេង សារី | អនុប្រធានការិ.នា. អកស | 011599995 |
| លោកស្រី វ៉ាន់ សុភី | អនុប្រធានការិ.នា. អកស | 012997386 |
| លោក យ៉ង់ កំស៊ាន | អនុប្រធានការិ.នា. អកស | 089575746 |
| លោក ស៊ឹម ចាន់សុវណ្ណារិទ្ធ | មន្ត្រី នា. បស | 012754741 |
| លោក ដាំ បេង | មន្ត្រីជំនាញ នា. អកស | 016720627 |
| កញ្ញា ឈុន សុរិយា | មន្ត្រីជំនាញ នា. អកស | 092192382 |
| លោកស្រី សេង ពិសិដ្ឋនារី | មន្ត្រីនា.អកស | 012850047 |
| លោក សុខ បញ្ញាវឌ្ឍន៍ | មន្ត្រីនា.អកស | 010220788 |
| លោកស្រី ទេព ប៉ុណ្ណារី | មន្ត្រីនា. អកស | 077767889 |

# ឧបសម្ព័ន្ធ ៤៖ បញ្ជីទំនាក់ទំនងរបស់មន្ទីរ និងដៃគូពាក់ព័ន្ធ

| ស្ថាប័ន/អង្គភាព | ឈ្មោះសមាជិកក្រុម | ឋានៈ និងតួនាទី | លេខទូរស័ព្ទ |
|---|---|---|---|
| មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបន្ទាយមានជ័យ | លោក ឈួ ប៊ុនរឿង<br>លោក តឿ សុខា<br>លោក សួន ពិដោរ | ប្រធានមន្ទីរ<br>ប្រធានការិ.អធិការកិច្ច<br>អនុការិ.ផែនការ | 092773088<br>077999960<br>089566630 |
| មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង | លោក យី សុងគី<br>លោក ម៉ក់ ម៉េង<br>លោក កា សម្បូរ | ប្រធានមន្ទីរ<br>អនុការិ.ផែនការស្ថិតិ<br>មន្ត្រីការិ.ផែនការ ស្ថិតិ | 012385377<br>092917316<br>012640103 |
| មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាម | លោក លី ម៉េងសាន<br>លោក ដា សុខចំរើន<br>លោក ជិន ថេន | ប្រធានមន្ទីរ<br>ប្រធានការិ.បឋម<br>មន្ត្រីការិ.បឋម | 011875048<br>012264203<br>012675872 |
| មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ឆ្នាំង | លោក គិត មិនារិទ្ធ<br>លោក សឹង សារឿន<br>លោក វ៉ឹង ចាន់ធី | អនុប្រធានមន្ទីរ<br>មន្ត្រីការិ.ផែនការ និង គ្រប់គ្រងជំនួយ<br>មន្ត្រីការិ.រដ្ឋបាល | 012401721<br>017238786<br>0973712900 |
| មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ | លោក ថន ថារិន<br>លោក ខៀវ សុមនោ<br>លោក ហៃ សំផា | ប្រធានមន្ទីរ<br>ប្រធានការិ.រដ្ឋបាល<br>អនុ.ការិ.អកត | 016308078<br>016622045<br>016446612 |
| មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ | លោក អ៊ិត វុឌ្ឍី<br>លោក សុក ឡេនីន<br>លោកស្រី សួន ចិន្តាមុនី | អនុប្រធានមន្ទីរ<br>ប្រធានការិ.មធ្យម<br>ប្រធានការិ.បឋម | 012859447<br>012948719/976222479<br>012682012 |
| មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពត | លោក សូ ភារិទ្ធ<br>លោក កង សម្ភស្ស<br>លោក រិន វីរៈ | អនុប្រធានមន្ទីរ<br>អនុការិ.បឋម<br>អនុការិ.យុវជន | 012257252<br>089697186<br>092311127 |
| មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្តាល | លោក ម៉ម ប៉ូលី<br>លោក ជា សុជា<br>លោក ឌុច ឧត្តម | អនុប្រធានមន្ទីរ<br>ប្រធាន ការិ. រប<br>មន្ត្រីការី. រប | 012966632<br>015303045<br>012919463 |
| មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកោះកុង | លោក ង៉ែត ឡឹង<br>លោក សុខ រីន<br>លោក ដេត វុទ្ធី | ប្រធានមន្ទីរ<br>ប្រធានការិ.បឋម<br>ប្រធានការិ.មធ្យម | 016858792<br>015284030/012531416<br>015582226 |

| ស្ថាប័ន/អង្គភាព | ឈ្មោះសមាជិកក្រុម | ឋានៈ និងតួនាទី | លេខទូរស័ព្ទ |
|---|---|---|---|
| មន្ទីរអប់រំ យុវជន និង កីឡា ខេត្តក្រចេះ | លោក ឡាយ បូរ៉ា<br>លោក ពុត សុភា<br>លោក ហេង ដា | ប្រធានមន្ទីរ<br>អនុប្រធានការិ.រដ្ឋបាល<br>មន្ត្រីការិ.រដ្ឋបាល | 012958174<br>017452006<br>011296777 |
| មន្ទីរអប់រំ យុវជន និង កីឡា ខេត្តមណ្ឌលគិរី | លោក ទឹម សង្ខាត<br>លោក គីម ប៊ុនធឿន<br>លោក ឡូយ  ចន្ទី | ប្រធានមន្ទីរ<br>អនុប្រធានមន្ទីរ<br>មន្ត្រីការិ.បឋមនិងមត្តេយ្យ | 012998028<br>012833718<br>012472593 |
| មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ | លោក ហែម ស៊ីណារ៉េត<br>លោក ហេង ឃីប<br>លោក ម៉ៅ ចាន់ថន | ប្រធានមន្ទីរ<br>មន្ត្រីការិ.បឋម<br>មន្ត្រីការិ.មធ្យម | 012840846<br>089509696<br>017552567 |
| មន្ទីរអប់រំ យុវជន និង កីឡា ខេត្តព្រះវិហារ | លោក ហេង សុខុម<br>លោក ព្រំ សម្ផស្ស<br>លោក កុយ ពុធមករា | អនុប្រធានមន្ទីរ<br>អនុការិ.គណនេយ្យសម្ភារៈ<br>មន្ត្រីការិ.មចទ | 077717127<br>099479057<br>0883466007 |
| មន្ទីរអប់រំ យុវជន និង កីឡា ខេត្តព្រៃវែង | លោក ប៉ាវ សុធីរ<br>លោក លាក់ ជ័យវុទ្ធី<br>លោក អែម ពិសិដ្ឋ | ប្រធានមន្ទីរ<br>អនុប្រធានការិ.មធ្យម<br>អនុប្រធានការិ.បឋម | 089740116<br>0977639063<br>012548777 |
| មន្ទីរអប់រំ យុវជន និង កីឡា ខេត្តពោធិ៍សាត់ | លោក លី សុគន្ធី<br>លោក គីម តុងហេង<br><br>លោក ផាង សុភ័ណ្ឌា | ប្រធានមន្ទីរ<br>អនុការិ.បុគ្គលិក និង<br>បណ្តុះបណ្តាល<br>អនុប្រធានការិ.បឋម | 016939816<br>015735007<br>095930192/070<br>505952 |
| មន្ទីរអប់រំ យុវជន និង កីឡា ខេត្តរតនគិរី | លោក ខាត់ សាម៉ាល់<br>លោក ស៊ូ មករា<br>លោក សួន ពេញ | ប្រធានមន្ទីរ<br>អនុប្រធានការិ.រដ្ឋបាល<br>មន្ត្រីការិ.រដ្ឋបាល | 0972233501/012<br>247432<br>012495476<br>0978333402 |
| មន្ទីរអប់រំ យុវជន និង កីឡា ខេត្តសៀមរាប | លោក សយ ទិត្យាវង្ស<br>លោក ចៅ បូរាណ<br>លោក រស់ សុវណ្ណ | ប្រធានមន្ទីរ<br>អនុប្រធានការិ.ផែនការ<br>មន្ត្រីការិ.ផែនការ | 012849171<br>012355685<br>011964757 |
| មន្ទីរអប់រំ យុវជន និង កីឡា ខេត្តព្រះសីហនុ | លោកស្រី អ៊ុច សោភា<br>លោក មាស ឌុល<br>លោក ម៉ាញ់ វ៉ារី | ប្រធានមន្ទីរ ស្តីទី<br>ប្រធានការិ.បឋម<br>អនុប្រធានការិ.មធ្យម | 098/077 855487<br>015502088/<br>099860090<br>069453746 |

| ស្ថាប័ន/អង្គភាព | ឈ្មោះសមាជិកក្រុម | ឋានៈ និងតួនាទី | លេខទូរស័ព្ទ |
|---|---|---|---|
| មន្ទីរអប់រំ យុវជន និង កីឡា ខេត្តស្ទឹងត្រែង | លោក ហ៊ាង ប៉ូលី<br>លោក យស់ ម៉ាច<br>លោក ឃួន សោភា | ប្រធានមន្ទីរ<br>អនុប្រធានមន្ទីរ<br>ប្រធានការិ.ផែនការ | 092431112<br>061978909/0977780746<br>012567854 |
| មន្ទីរអប់រំ យុវជន និង កីឡា ខេត្តស្វាយរៀង | លោក ខៀវ សំអុល<br>លោក សួស ឌីណា<br>លោក ម៉ែន សំអាន | ប្រធានមន្ទីរ<br>ប្រធានការិ.រដ្ឋបាល<br>មន្ត្រីការិ.រដ្ឋបាល | 0889971999<br>0974821844<br>0977123291 |
| មន្ទីរអប់រំ យុវជន និង កីឡា ខេត្តតាកែវ | លោក ហម នីម៉ុន<br>លោក កយ បូរិទ្ធ<br>កញ្ញា ចាន់ វណ្ណៈ | អនុប្រធានមន្ទីរ<br>អនុការិ.រដ្ឋបាល<br>អនុការិ.បឋម | 012884911<br>016667525<br>012303862 |
| មន្ទីរអប់រំ យុវជន និង កីឡាខេត្តឧត្តរមានជ័យ | លោក ឈឺន ឈា<br>លោក នុត ប៊ុនធួន<br>លោក ហៀង ជៀបហេង | អនុប្រធានមន្ទីរ<br>ប្រធានការិ.ផែនការ<br>មន្ត្រីការិ.ផែនការ | 012214975/0889900496<br>012608577/0972559986<br>092862030/0974132151 |
| មន្ទីរអប់រំ យុវជន និង កីឡា ខេត្តកែប | លោក ងួន ច័ន្ទសុជាតា<br>លោក ម៉ាត់ អ៊ីសើ<br>លោកស្រី ឈឹម រ៉ាន្នី | ប្រធានមន្ទីរ<br>អនុការិ.អធិការកិច្ច<br>អនុការិ.រដ្ឋបាល | 012710488<br>017950804/0712141300<br>092151451 |
| មន្ទីរអប់រំ យុវជន និង កីឡា ខេត្តប៉ៃលិន | លោក ជា អិត<br>លោក សុន សំអិត<br>លោកស្រី ពាក សារ៉ន | អនុប្រធានមន្ទីរ<br>មន្ត្រីការិ.បុគ្គលិក<br>មន្ត្រីការិ.បុគ្គលិក | 017493232<br>016822089<br>0964270896 |
| មន្ទីរអប់រំ យុវជន និង កីឡា ខេត្តត្បូងឃ្មុំ | លោក អ៊ិន ពៅសម្បត្តិ<br>លោក នួន ស៊ីវ៉ាញឿន<br>លោក ខៃ សំអាត | ប្រធានមន្ទីរ<br>អនុប្រធានមន្ទីរ<br>ប្រធានការិ.រដ្ឋបាល | 012418929<br>012877736<br>092595388 |

## បញ្ជីទំនាក់ទំនងរបស់ដៃគូក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំ

| ឈ្មោះសមាជិកក្រុម | ស្ថាប័ន | លេខទូរស័ព្ទ |
|---|---|---|
| Mr. Chum Chanra | UNICEF | 012440170 |
| Mr. Chanborith ROS | Save the Children | 012676239 |
| Mr. Pel Piseth | Plan International | 017951456 |
| Mr. Chorn Bunly | World Vision | 098507788 |
| Mr. Chen Tep Samol | ChildRights Foundation | 017727848 |
| Ms. Keo Socheat | ChildFund Cambodia | 012487276 |
| Ms. Mith Somountha | ActionAid | 078227785 |

# ឧបសម្ព័ន្ធ ៥៖ ផែនទីនៃតំបន់គោលដៅរបស់អង្គការដៃគូពាក់ព័ន្ធក្នុងឆ្នាំ២០១៨




Who Works Where Map — Joint Action Group for DRR updated by late 2018

# ឧបសម្ព័ន្ធ ៦៖ ស្តង់ដាសម្ភារៈសិក្សា សម្រាប់បង្កើតកន្លែងរៀនបណ្តោះអាសន្ន

| សម្ភារៈ និងឧបករណ៍សម្រាប់រៀបចំកន្លែងរៀនបណ្តោះអាសន្ន - សម្រាប់ផ្តល់គ្រូបង្រៀន | | | |
|---|---|---|---|
| មុខទំនិញ | តម្លៃក្នុងមួយឯកតា | បរិមាណ ឬ ខ្នាត | សរុប |
| ១. កៅស៊ូតង់ | | | |
| ២. ធុងចម្រោះទឹក | | | |
| ៣. ក្តារខៀនស | | | |
| ៤. ហ្វឺតសរសេរក្តារខៀន | | | |
| ៥. សាប៊ូដុំ | | | |
| ៦. កន្សែងពោះគោតូច | | | |
| ៧. សម្ភារៈសម្រាប់គូរគំនូរ | | | |
| ៨. សម្ភារៈលេងកីឡា | | | |
| សរុប | | | |

| សម្ភារៈសិក្សាសម្រាប់ផ្តល់ឱ្យកុមាររងគ្រោះ (ជាមធ្យម ៣៥ នាក់ សម្រាប់មួយកន្លែងរៀន) | | | |
|---|---|---|---|
| មុខទំនិញ | តម្លៃក្នុងមួយឯកតា | បរិមាណ ឬ ខ្នាត | សរុប |
| ១. កាតាប មានភ្ជាប់ជាមួយពោង | | | |
| ២. សៀវភៅសរសេរ | | | |
| ៣. ប៊ិក | | | |
| ៤. ខ្មៅដៃ | | | |
| ៥. ជ័រលុប | | | |
| ៦. ប្រដាប់ចិតខ្មៅដៃ | | | |
| ៧. ប្រអប់ឬកាបូបដាក់ប៊ិក ខ្មៅដៃ | | | |
| ៨. ដបសម្រាប់ដាក់ទឹកញ៉ាំ | | | |

# ឧបសម្ព័ន្ធ ៧៖ ឧបករណ៍សម្រាប់ប៉ាន់ប្រមាណឆាប់រហ័សអំពីផលប៉ះពាល់នៃគ្រោះមហន្តរាយលើវិស័យអប់រំ

| | |
|---|---|
| ១.អ្នកធ្វើរបាយការណ៍ | 01. ឈ្មោះ៖ ______________________<br>02. តួនាទី៖ ______________________<br>03. មន្ទីរអេយក. ខេត្ត៖__________________ |
| ២.កាលបរិច្ឆេទនៃគ្រោះអាសន្ន (Date of disaster): | …………/…………./20……… |
| ៣. ប្រភេទគ្រោះមហន្តរាយ Type of Disaster *(គូសរង្វង់សម្រាប់ចម្លើយដែលសមស្រប Circle appropriate answer)* | រាំងស្ងួត Drought 03. ខ្យល់ព្យុះ Storm<br>ទឹកជំនន់ Flood 99. ផ្សេងៗ (សូមបញ្ជាក់) Other (specify)<br>________________________________ |

| ៤.ចំនួនសាលារៀនដែលរងផលប៉ះពាល់ | | |
|---|---|---|
| សូមបញ្ជាក់ចំនួន Please specify numbers | អំឡុងពេលគ្រោះមហន្តរាយ/ During disaster | |
| | i. ដំណើរការ Functioning | ii. បិទ Closed |
| a. ចំនួនសាលាមត្តេយ្យ Pre-school * | | |
| b.ចំនួនសាលាបឋមសិក្សា Primary school * | | |
| c. ចំនួនសាលាមធ្យមសិក្សាបឋមភូមិ Secondary school * | | |
| d. ចំនួនសាលាមធ្យមសិក្សាទុតិយភូមិ High school * | | |

| ៥.សូមសរសេររៀបរាប់ឈ្មោះសាលារៀននីមួយៗ ផ្អែកទៅតាមទីតាំង និងតម្រូវការ ?<br>List each by Location and Need ? | | |
|---|---|---|
| ឈ្មោះសាលា<br>Name of schools | ទីតាំងនៅក្នុងឃុំ<br>Location in commune | តម្រូវការ<br>Needs |
| | | |
| | | |
| | | |
| | | |

| | |
|---|---|
| ៦. តើការខាតបង់ការសិក្សាច្រើនបំផុតមានប៉ុន្មានថ្ងៃ តាមសាលារៀនដែលមាននៅក្នុងតំបន់ដែលរងគ្រោះ?<br>( សូមកាត់ត្រាចំនួនថ្ងៃពីសាលាដែលខាតបង់ការសិក្សាច្រើនបំផុតបានហើយ )<br>What is the maximum_number of school days lost by schools in the area ?<br>( note # of days from school that has lost the most days ) | ___________<br>_______ |

| ៧. សូមបញ្ជាក់ចំនួនសំណង់ដែលខូចខាត (Please specify numbers of school facilities affected) | កម្រិតខូចខាតនៃរូបវន្តរបស់សាលារៀន School physical damage rating | | | |
|---|---|---|---|---|
| | 0-30% អាចប្រើបាន ត្រូវជួសជុលតិចតួច Useable/ need minor repairs | 30-60% អាចប្រើបានត្រូវជួសជុលច្រើន Useable/ need major repairs | 60-100% មិនអាចប្រើបាន មានការខូច ខាតច្រើន Unusable with major damage | យោបល់ Comments |
| a. ចំនួនអណ្តូង # well | | | | |
| b. ចំនួនបង្គន់ # latrine | | | | |
| c. ចំនួនបន្ទប់រៀន # classrooms | | | | |
| d.ចំនួនអគារសិក្សា # of school building | | | | |
| e. ចំនួនសួនកុមារលេង # of playground | | | | |
| f. ចំនួនរបងសាលា # of school fence | | | | |
| g. ផ្សេងៗ other | | | | |

| | |
|---|---|
| ៨.នៅពេលបច្ចុប្បន្ន តើមានសិស្សប្រហែលប៉ុន្មាននាក់ដែលគ្រប់អាយុសម្រាប់សិក្សានៅថ្នាក់បឋម និងថ្នាក់មធ្យមសិក្សា មិនមករៀននៅសាលារៀន ឬមិនមករៀននៅទីកន្លែងបង្រៀនបណ្ដោះអាសន្ន ? About how many children of primary or secondary-school age are not attending school or Temporary Learning Spaces now ? | **សិស្សគ្រប់អាយុសម្រាប់ថ្នាក់បឋមសិក្សា Primary school-age students**<br>សិស្សប្រុស Boys ________<br>សិស្សស្រី Girls ________<br>**សិស្សគ្រប់អាយុសម្រាប់មធ្យមសិក្សា Secondary school-age students**<br>សិស្សប្រុស Boys _________<br>សិស្សស្រី Girls __________ |
| ៩.តើមានទីកន្លែងរៀន/សាលារៀនបណ្ដោះអាសន្នកំពុងដំណើរការដែរឬទេ ? Are there any Temporary Learning Spaces/School operating ( TLS ) ? | មាន Yes<br>បើមាន សូមកត់ត្រាទីតាំងទាំងនេះ<br>If yes, please list locations<br>…………………………………………<br>……………………………………….<br>…………………………………………<br>……………………………………….<br>តើមានការផ្ដល់សម្ភារៈរៀន និងបង្រៀនដល់សិស្ស និងគ្រូ ដែរទេ ?បើមាន អ្វីខ្លះ ?<br>…………………………………………<br>……………………………………….<br>…………………………………………<br>……………………………………….<br>…………………………………………<br>……………………………………….<br>មិនមាន No |

| ១០.កត្តាសំខាន់ៗអ្វីខ្លះដែលរារាំងកុមារក្នុងការទៅសាលារៀន (រៀបតាមលំដាប់នៃអាទិភាព, 1=អាទិភាពខ្ពស់បំផុត)<br>Main barriers preventing school access (list in order of priority, 1=highest) | |
|---|---|
| a. សាលារៀនបិទ ដោយសារតែគ្រោះមហន្តរាយ ឬខូចខាត<br>School closed due to disaster or damage | |
| b. ឪពុកម្តាយបារម្ភពីបញ្ហាសុវត្ថិភាព<br>Parents concerned about safety | |
| c. ទុកកូននៅផ្ទះដើម្បីជួយការងារដើម្បីឆ្លើយតបគ្រោះមហន្តរាយ ឬធ្វើការងារផ្សេងទៀត<br>Children kept home to help respond to disaster/work | |
| d. មិនមានមធ្យោបាយធ្វើដំណើរ<br>No/limited transport | |
| e. ផ្លូវមិនអាចធ្វើដំណើរបាន<br>Roads inaccessible | |
| f. មិនមានគ្រូបង្រៀនគ្រប់គ្រាន់<br>No/insufficient teachers | |
| g. មិនមានសម្ភារៈសិក្សា/សៀវភៅ<br>No education materials/books | |
| h. ផ្សេងៗ (សូមបញ្ជាក់)<br>Other (Specify) | |

| | |
|---|---|
| ១១.តើមានតម្រូវការជាអាទិភាពបន្ទាន់អ្វីខ្លះ សម្រាប់សាលារៀននេះ? | |

| ១២. តើសាលារៀនបានទទួលជំនួយដែរឬទេ ?បើមាន តើប្រភេទជំនួយអ្វីខ្លះដែលត្រូវបានផ្តល់ឱ្យ និងមានបរិមាណប៉ុន្មាន ? ( ឧ. ប្រភេទ និងបរិមាណគិតជាគីឡូក្រាមនៃស្បៀងអាហារ ) What kind of assistance has been provided and what amount ( e.g. type & kg of food ) | | | | |
|---|---|---|---|---|
| ប្រភេទជំនួយ<br>Kind of assistance | ពីអ្នកណា ?<br>From whom ? | ផ្តល់ទៅឱ្យប៉ុន្មានសាលា ?<br>To how many school ? | ផ្តល់នៅកន្លែងណា ?<br>Where ? | ផ្តល់ឱ្យនៅពេលណា ?<br>When ? |
| | | | | |
| | | | | |
| | | | | |
| | | | | |

| ១៣.តើអ្នកបានដឹងពីជំនួយណាមួយ ឬអង្គការណាខ្លះដែលត្រូវបានគ្រោងនឹងផ្តល់ឱ្យនាពេលខាងមុខដែរឬទេ ? Are you aware of any future planned assistance? ( បើមិនដឹង សូមរំលងទៅសំណួរទី១៤ ) | ☐ ដឹង Know<br>☐ មិនដឹង Don't Know |
|---|---|

| ១៤.ប្រសិនបើមាន តើប្រភេទជំនួយអ្វីខ្លះ ? If yes, what kind of assistance ? | | | |
|---|---|---|---|
| ប្រភេទជំនួយ<br>Kind of assistance | ពីអ្នកណា ?<br>From whom ? | ផ្តល់ទៅឱ្យប៉ុន្មានសាលា ?<br>For how many school ? | តើនៅពេលណា ?<br>When ? |
| | | | |
| | | | |
| | | | |
| | | | |

| ១៥.ការផ្តល់យោបល់ និងការសង្កេតផ្សេងៗ Comments and Observations: | |
|---|---|
| សូមសរសេរបន្ថែមនូវព័ត៌មានផ្សេងៗ នៅខាងក្រោមនេះ<br><br>Please note anything additional in the space below. | ………………………………………………………………<br>………………………………………………………………<br>………………………………………………………………<br>………………………………………………………………<br>………………………………………………………………<br>………………………………………………………………<br>………………………………………………………………<br>……………………………………………………………… |

# ឧបសម្ព័ន្ធ ៨៖ សទ្ទានុក្រម

| | |
|---|---|
| ការគ្រប់គ្រងគ្រោះមហន្តរាយ | សំដៅដល់សកម្មភាពមួយចំនួនមុនពេល ក្នុងពេល និងក្រោយពេល គ្រោះមហន្តរាយ ដើម្បីថែរក្សាការ ត្រួតពិនិត្យ តាមដានពីគ្រោះមហន្តរាយ និងផ្តល់ក្របខ័ណ្ឌការងារសម្រាប់ជួយដល់មនុស្ស ដែលស្ថិត ក្នុងហានិភ័យ ឬសហគមន៍ណាមួយ ដើម្បីបញ្ចៀសកាត់បន្ថយជាអប្បបរមា ឬធ្វើឱ្យមានប្រក្រតីភាព ឡើងវិញពីផលប៉ះពាល់នៃគ្រោះមហន្តរាយ។ |
| ការកាត់បន្ថយគ្រោះថ្នាក់ | សំដៅដល់វិធានការបែបរចនាសម្ព័ន្ធ និងបែបមិនមែនរចនាសម្ព័ន្ធ ដើម្បីទទួលធ្វើ ដើម្បីកម្រិតផល ប៉ះពាល់ មិនល្អនៃមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ការខូចខាតបរិស្ថាន និងមុខសញ្ញាគ្រោះថ្នាក់ខាង បច្ចេកទេស។ ឧទាហរណ៍ វិធានការបែបរចនាសម្ព័ន្ធ ជាការងារវិស្វកម្ម ការកសាងទប់ទល់មុខសញ្ញា គ្រោះថ្នាក់ ចំណែកវិធានការបែបមិនមែនរចនាសម្ព័ន្ធ រួមមានការបង្កើនការយល់ដឹង ការអភិវឌ្ឍចំណេះ ដឹង គោលនយោបាយ ផែនការប្រើប្រាស់ដី និងគ្រប់គ្រងធនធាន និងការអនុវត្តប្រតិបត្តិការមធ្យោបាយនានា។ |
| ការត្រៀមបង្ការ | សំដៅដល់សកម្មភាព ដើម្បីបញ្ចៀសទាំងស្រុងពីផលប៉ះពាល់បណ្តាលមកពីមុខសញ្ញាគ្រោះថ្នាក់ និងជា មធ្យោបាយ ដើម្បីបន្ថយជាអតិបរមាទាក់ទងនឹងគ្រោះមហន្តរាយ នៃបរិស្ថានបច្ចេកវិទ្យានិងជីវសាស្ត្រ។ |
| ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | សំដៅដល់ទស្សនាទាន និងការអនុវត្តតាមរយៈការខិតខំប្រឹងប្រែងជាប្រព័ន្ធដើម្បីវិភាគ និងគ្រប់គ្រងកត្តា ដែលអាចកើតមានគ្រោះមហន្តរាយ រួមទាំងការកាត់បន្ថយកម្រិតគ្រោះថ្នាក់នៃមុខសញ្ញាគ្រោះថ្នាក់ ធ្វើឱ្យតិចនូវភាពងាយរងគ្រោះរបស់មនុស្ស ទ្រព្យសម្បត្តិ របៀបគ្រប់គ្រងដីធ្លី បរិស្ថាន និងពង្រឹងការត្រៀម រៀបចំសម្រាប់ព្រឹត្តិការណ៍អាក្រក់នានា។ |
| ការយល់ដឹងជាសាធារណៈ | សំដៅដល់ការពង្រីកចំណេះដឹងទូទៅអំពីហានិភ័យគ្រោះមហន្តរាយ ដែលជាកត្តានាឱ្យមាន គ្រោះ មហន្តរាយ និងសកម្មភាពអនុវត្តបានដោយបុគ្គល និងដោយសមូហភាពដើម្បីកាត់បន្ថយ ការប្រឈម មុខនឹងភាពងាយរងគ្រោះ ទៅនឹងមុខសញ្ញាគ្រោះថ្នាក់នានា។ |
| ការឆ្លើយតប | សំដៅដល់ការផ្តល់សេវាកម្មសង្គ្រោះបន្ទាន់ និងជំនួយសាធារណៈ នៅក្នុងពេលនិងក្រោយពេល មាន គ្រោះមហន្តរាយ ដើម្បីជួយសង្គ្រោះ កាត់បន្ថយផលប៉ះពាល់លើសុខភាព ជានាសុវត្ថិភាពសាធារណៈ និងដោះស្រាយសេចក្តីត្រូវការសម្រាប់ការចិញ្ចឹមជីវិតជាមូលដ្ឋាន របស់ប្រជាជន ដែលទទួលរងផល ប៉ះពាល់។ |

| | |
|---|---|
| ការប៉ាន់ប្រមាណហានិភ័យ | សំដៅដល់វិធីសាស្ត្រដើម្បីកំណត់លក្ខណៈ និងកម្រិតហានិភ័យដោយធ្វើការវិភាគមុខសញ្ញាគ្រោះថ្នាក់ ដែលអាចកើតមាន និងវាយតម្លៃលើលក្ខខណ្ឌដែលមានស្រាប់ នៃភាពងាយរងគ្រោះ ដែលកត្តាទាំងពីរ នេះអាចបង្កមហន្តរាយដល់មនុស្ស ទ្រព្យសម្បត្តិ សេវាកម្មជីវភាព រស់នៅ និងបរិស្ថាន។ |
| គ្រោះមហន្តរាយ | សំដៅដល់ការរំខានដ៏ធ្ងន់ធ្ងរនៃដំណើរការរបស់សហគមន៍ ឬសង្គម ដែលធ្វើឱ្យមានការបាត់បង់ និង ប៉ះពាល់ធ្ងន់ធ្ងរដល់មនុស្ស សម្ភារៈ សេដ្ឋកិច្ច ឬបរិស្ថាន ដែលកម្រិតនៃការប៉ះពាល់ហួសពីសមត្ថភាព របស់សហគមន៍ ឬសង្គម ដែលទទួលរងការប៉ះពាល់ ក្នុងការប្រើប្រាស់ លៃលកដោះស្រាយដោយធនធានខ្លួនឯង។ |
| គ្រោះអាសន្ន | សំដៅដល់ការគំរាមកំហែងដែលតម្រូវឱ្យមានសកម្មភាពបន្ទាន់ប្រកបដោយប្រសិទ្ធភាព ដែលអាច បញ្ចៀសនូវការរីកធំឡើងនៃព្រឹត្តិការណ៍ដែលឈានដល់គ្រោះមហន្តរាយ។ |
| ប្រព័ន្ធប្រកាសឱ្យដឹងមុន | សំដៅដល់សមត្ថភាព ដែលតម្រូវឱ្យមានការបង្កើនសម្រាប់ប្រមូល និងផ្សព្វផ្សាយទាន់ពេលវេលា និង ប្រកកាសព័ត៌មានដែលមានន័យគ្រប់គ្រាន់ ទៅដល់ក្រុមមនុស្ស សហគមន៍ និងស្ថាប័នដែលគំរាមកំហែងដោយមុខសញ្ញាគ្រោះថ្នាក់ ដើម្បីត្រៀមធ្វើឱ្យសមស្រប និងទាន់ពេលវេលា ពីការកាត់បន្ថយ លទ្ធភាពនៃការអន្តរាយ ឬបាត់បង់។ |
| ផែនការត្រៀមបម្រុង | សំដៅដល់ការគ្រប់គ្រងដំណើរការដែលធ្វើការវិភាគលើព្រឹត្តិការណ៍កើតឡើង ឬស្ថានភាពអាចកើតឡើង ហើយអាចគម្រាមសង្គម ឬបរិស្ថាន និងការរៀបចំទុកជាក់ ដើម្បីចាត់ចែងពេលខាងមុខ ប្រកបដោយ សមត្ថភាព និងទាន់ពេលទៅនឹងព្រឹត្តិការណ៍ និងស្ថានភាពទាំងនោះ។ |
| ភាពងាយរងគ្រោះ | សំដៅដល់លក្ខខណ្ឌ ដែលកំណត់ដោយកត្តារូបវន្ត សង្គម និងបរិស្ថាន ឬដំណើរការ ដែលបង្កើនភាព ចុះខ្សោយរបស់សហគមន៍ទៅនឹងផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់។ |
| ភាពធន់ | សំដៅដល់សមត្ថភាព ប្រព័ន្ធសហគមន៍ ឬសង្គមដែលប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់ ដើម្បីទប់ទល់ សម្របទៅតាម និងស្តារពីផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ឱ្យបានទាន់ពេល និងមានប្រសិទ្ធភាព តាមរយៈសកម្មភាពនានា ដោយសិក្សាពីគ្រោះមហន្តរាយ ពីអតីតកាលឱ្យមានការប្រុងប្រយ័ត្ននាពេល អនាគត និងចាត់វិធានការឱ្យប្រសើរឡើងនូវការកាត់បន្ថយហានិភ័យ។ |

| | |
|---|---|
| មុខសញ្ញាគ្រោះថ្នាក់ | សំដៅដល់ព្រឹត្តិការណ៍ បាតុភូតមួយ ឬសកម្មភាពរបស់មនុស្ស ដែលសក្តានុភាពដែលអាចធ្វើឱ្យខូចខាត ជារូបវន្ត រួមមានការបាត់បង់អាយុជីវិត រងរបួស ខូចខាត និងធ្វើបាត់បង់ទ្រព្យសម្បត្តិ រាំងស្ទះដល់សង្គម និងសេដ្ឋកិច្ច ឬខូចខាតបរិស្ថាន ។ |
| ហានិភ័យ | សំដៅដល់ភាពដែលអាចកើតមាននូវផលវិបាក ការធ្វើទុក្ខទោស ឬការបាត់បង់ដែលបានរំពឹងទុក (ស្លាប់ របួស ទ្រព្យសម្បត្តិ ជីវភាព សកម្មភាពសេដ្ឋកិច្ច ត្រូវបានរំខាន ឬបរិស្ថានត្រូវបានខូចខាត) បណ្តាលមក ពីអន្តរកម្មរវាងមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិឬមនុស្ស ទៅនឹងភាពងាយរងគ្រោះ។ |
| ហានិភ័យគ្រោះមហន្តរាយ | សំដៅដល់អនុភាពនៃការបាត់បង់ដោយគ្រោះមហន្តរាយ លើអាយុជីវិត សុខភាព ជីវភាពរស់នៅ ទ្រព្យសម្បត្តិ និងសេវាកម្មនានា ដែលអាចកើតមានឡើង ចំពោះសហគមន៍ ឬសង្គមនៅពេលមួយ ក្នុងពេលអនាគត។ |
| ការការពារគ្រោះមហន្តរាយ | សំដៅដល់សកម្មភាព និងវិធានការ ដើម្បីបញ្ចៀសផលប៉ះពាល់ ដែលមិនអនុគ្រោះនៃមុខសញ្ញាគ្រោះ ថ្នាក់ ឬ សកម្មភាពទាំងឡាយណា ដែលត្រូវបានគេរចនាឡើង ដើម្បីផ្តល់នូវការការពារជាអចិន្ត្រៃយ៍ ពីគ្រោះមហន្តរាយឬបញ្ឈប់គ្រោះមហន្តរាយមិនឱ្យកើតមានឡើង។ ឧ.ការទប់ស្កាត់ ឬលុបបំបាត់ មុខសញ្ញាគ្រោះថ្នាក់ដូចជាៈ អគ្គិភ័យ រាំងស្ងួត ទឹកជំនន់ និងការបង្កើនសមត្ថភាព និងការលុបបំបាត់ ភាពងាយរងគ្រោះ ដើម្បីការពារមិនឱ្យមានគ្រោះមហន្តរាយកើតឡើង ដូចជាការសាងសង់លំនៅដ្ឋាន រឹងមាំ និងផុតពីកម្ពស់ទឹកដែលអាចធន់នឹងខ្យល់ព្យុះ ឬទឹកជំនន់។ល។ |
| សមត្ថភាព | សំដៅដល់ចំណេះដឹង ជំនាញ ធនធាន លទ្ធភាពនិងកម្លាំងដែលមានក្នុងបុគ្គល គ្រួសារ សហគមន៍ ស្ថាប័ននានា ដែលអាចធ្វើឱ្យពួកគេមានលទ្ធភាពទប់ទល់បាន ដូចជាការត្រៀមបង្ការ ការកាត់ បន្ថយគ្រោះមហន្តរាយ ឬការស្តារ ឡើងវិញ បន្ទាប់ពីគ្រោះមហន្តរាយ បានទាន់ពេលវេលា។ |
| ការបន្សុាំ | សំដៅដល់ការកែតម្រូវនៅក្នុងប្រព័ន្ធធម្មជាតិ ឬប្រព័ន្ធមនុស្ស ដើម្បីឆ្លើយតបនឹងកត្តាជុំវិញអាកាសធាតុ ជាក់ស្តែង ឬរំពឹងទុក ឬផលប៉ះពាល់អាកាសធាតុ ដែលបន្ថយគ្រោះថ្នាក់ នឹងទទួលបានឱកាសដែល មានប្រយោជន៍។ |
| ការប្រែប្រួលអាកាសធាតុ | សំដៅដល់ការប្រែប្រួលដែលសង្កេតឃើញនៅក្នុងអាកាសធាតុ កម្រិតសកលតំបន់ ឬអនុតំបន់ ដែល បណ្តាលមកពីដំណើរការធម្មជាតិ និង/ឬសកម្មភាពមនុស្ស។ |

| | |
|---|---|
| ការឆ្លើយតបគ្រោះអាសន្ន | សំដៅដល់សកម្មភាពដែលត្រូវបាន អនុវត្តនៅក្នុងស្ថានភាពគ្រោះមហន្តរាយ ក្នុងគោលបំណងសង្គ្រោះ ជីវិត សម្រាលទុក្ខវេទនា និងកាត់បន្ថយការខាតបង់សេដ្ឋកិច្ច។ |
| ការស្តារឡើងវិញ | សំដៅដល់សកម្មភាពដើម្បីជួយជនរងគ្រោះឱ្យទៅស្ថានភាពនៃការរស់នៅជាធម្មតា ហើយនឹងត្រូវបានគេ ធ្វើសមាហរណកម្មឡើងវិញទៅក្នុងមុខងារសហគមន៍ដែលមានលក្ខណៈជាធម្មតាថែមទាំងបូកបញ្ចូលនូវ ការស្តារឱ្យមានលក្ខណៈដូចដើមនូវសេវាកម្មសាធារណៈដែលអាចជួសជុលបាន កែលំអលំនៅដ្ឋានឬ ការតាំងលំនៅថ្មីឡើងវិញ ជួសជុលហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំផ្សេងទៀត រួមទាំងការផ្តល់សេវាកម្ម នៃមធ្យោបាយសម្រាប់ការស្តារជីវភាពរស់នៅជាថ្មីឡើងវិញ។ |
| ការកសាងឡើងវិញ | សំដៅដល់សកម្មភាពធ្វើឱ្យប្រសើឡើងនូវការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនានាដែលទទួលរងការ បំផ្លិចបំផ្លាញធ្ងន់ធ្ងរ ឬទាំងស្រុងដោយសាមុខសញ្ញាគ្រោះមហន្តរាយ ដើម្បីនាំសហគមន៍ទៅរកភាព ធម្មតាឡើងវិញ និងឈានទៅរកការអភិវឌ្ឍ។ ឧ. កសាងលំនៅដ្ឋាន សំណង់អគារសាធារណៈ ដូចជា សាលារៀនមន្ទីរពេទ្យ វត្តអារាម ផ្លូវថ្នល់ បណ្តាញទឹកស្អាត អគ្គិសនី ទំនប់ទឹក និងប្រព័ន្ធធារាសាស្ត្រ ។ល។ |
| ការអភិវឌ្ឍ | សំដៅដល់ដំណើការមួយ ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរគ្រប់វិស័យដូចជា សេដ្ឋកិច្ចវប្បធម៌ វិទ្យាសាស្ត្រ និងសង្គម កិច្ច ឆ្ពោះទៅរកភាពរីកចំរើន និងភាពសុខដុមរម្យនានៃជីវភាពរស់នៅរបស់មនុស្ស។ ឧ. ការ លើកកម្ពស់ គុណភាពនៃជីវិត ដំណើរការលើកកម្ពស់ស្មារតីប្រជាជន ការធ្វើឱ្យប្រសើរឡើងនូវស្ថានភាព សេដ្ឋកិច្ចជីវភាព រស់នៅ និងទីជម្រក អាហារ ទឹក បរិស្ថាន អនាម័យ និង សុខភាព។ |
| សេនដាយ | សំដៅដល់ក្របខ័ណ្ឌការងារសេនដាយ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០១៥ ដល់ ២០៣០ ដែលត្រូវបានអនុម័តនៅឯសន្និសីទពិភពលោកលើកទី៣ នៃអង្គការសហប្រជាជាតិ នៅ ទីក្រុងសេនដាយ ប្រទេសជប៉ុននាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៥។ |
| កិច្ចព្រមព្រៀងអាស៊ាន | សំដៅដល់កិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបគ្រោះអាសន្ន។ កិច្ចព្រមព្រៀងអាស៊ានគឺជាក្របខ័ណ្ឌការងារថ្នាក់តំបន់សម្រាប់កិច្ចសហប្រតិបត្តិការសម្របសម្រួល ជំនួយបច្ចេកទេសគ្រប់ផ្នែកនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការកៀរគរធនធាន សម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ។ កិច្ចព្រមព្រៀងអាស៊ាន ត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីការបរទេស សមាជិក អាស៊ានទាំង១០ នាទីក្រុងវៀងច័ន្ទ ប្រទេសឡាវ នៅខែកក្កដាឆ្នាំ២០០៥។ |

| | |
|---|---|
| ការចូលរួម | ដំណើរការមួយដែលអង្គការធ្វើការទាក់ទង ពិគ្រោះយោបល់ និង/ឬផ្តល់ឱ្យមានការចូលរួមពីគ្រប់ភាគី ដែលពាក់ព័ន្ធដើម្បីធានាថារាល់កង្វល់ បំណង ការរំពឹងទុក សេចក្តីត្រូវការ សិទ្ធិ និងឱកាសរបស់ពួកគេ ត្រូវបានពិចារណា ក្នុងការបង្កើត អនុវត្ត និងពិនិត្យកម្មវិធីទាំងនោះដើម្បីជួយដល់ពួកគេ។ |
| សកម្មភាពមនុស្សធម៌ | សកម្មភាពមួយដែលមានគោលបំណងសង្គ្រោះជីវិត កាត់បន្ថយការរងទុក្ខវេទនា និងរក្សាបាននូវសេចក្តី ថ្លៃថ្នូររបស់មនុស្សក្នុងអំឡុងពេល និងបន្ទាប់ពីគ្រោះមហន្តរាយធម្មជាតិ និងដោយមនុស្ស ក៏ដូចជា សកម្មភាពផ្សេងទៀត ដើម្បីការពារ និងរៀបចំ។ |
| អង្គការ | អង្គភាពដែលមានរចនាសម្ព័ន្ធគ្រប់គ្រង និងអំណាច ដើម្បីអនុវត្តបទដ្ឋានស្នូលជំនួយមនុស្សធម៌។ |
| ដៃគូ | អង្គការដែលធ្វើការរួមគ្នា ដោយមានការរៀបចំជាផ្លូវការ ដើម្បីសម្រេចបាននូវគោលដៅជាក់លាក់ ដោយ មានតួនាទី ការទទួលខុសត្រូវព្រមព្រៀងគ្នា និងច្បាស់លាស់។ |
| បុគ្គលិក | ជាអ្នកតំណាងរបស់អង្គការមួយ គិតរួមបញ្ចូលទាំងបុគ្គលិកជាតិ អន្តរជាតិ និងអចិន្ត្រៃយ៍ ឬរយៈពេលខ្លី ក៏ដូចជាអ្នកស្ម័គ្រចិត្ត និងទីប្រឹក្សាផងដែរ។ |

***កំណត់សម្គាល់:*** *សទ្ទានុក្រមគ្រោះមហន្តរាយ ខាងលើនេះគឺយោងតាមឯកសារដូចខាងក្រោម៖*

*១. ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ឆ្នាំ២០១៥*

*២. ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់វិស័យអប់រំ ឆ្នាំ២០១៤*

*៣. បទដ្ឋានស្នូលមនុស្សធម៌ស្តីពីគុណភាព និងគណនេយ្យភាព ឆ្នាំ២០១៤*

លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ
ក្រសួងអប់រំ យុវជន និងកីឡា

Disaster Management Secretariat
Ministry of Education, Youth and Sport
(DMS. MoEYS)

គាំទ្របច្ចេកទេសដោយ

unicef
Save the Children 100 YEARS
PLAN INTERNATIONAL
អង្គការមូលនិធិសិទ្ធិកុមារ Child Rights Foundation Organization
World Vision
ChildFund Cambodia
actionaid

Frontpage photos credit: Save the Children